# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម

២០-៩-២០១២ -ព្រះរាជក្រម នស/រកម/០៩១២/០០៩ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញារ៉ូធើដាម ស្តីពីនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុនចំពោះសារធាតុគីមី និង ថ្នាំកសិកម្មគ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ ៧១៩៩

### ២~ព្រះរាជក្រឹត្យ

១៧-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨២៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ៧១ រូប ៧២៨៤

១៧-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨៣៨ ស្តីពី ការតែងតាំងឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជា កិត្តិសេដ្ឋាបណ្ឌិត នៃរាជបណ្ឌិត្យសភាកម្ពុជា ៧២៨៦

១៧-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨៣៩ ស្តីពី ការតែងតាំងលោក **គង់ ម៉ុនហាង** ជា ឧកញ៉ា ៧២៨៧

១៧-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨៤០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះមន្ត្រីរាជការ និងសប្បុរសជន ចំនួន ១៧៩ រូប ៧២៨៨

១៧-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨៤១ ស្តីពី ការតម្លើងឋានន្តរស័ក្តិជូនមន្ត្រីរាជការចំនួន ០២ រូប ពីឋានន្តរស័ក្តិវរមន្ត្រី ទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ៧២៩២

*19 – 9 -2012 - KRET NS/ 0912/842 NOMMONS à titre posthume Monsieur Peter Chrenhaft, Grang Officier de l'Ordre Royal du Sahamétrei, en témoignage de Notre très haute considération.* ៧២៩៣

១៩-៩-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៩១២/៨៤៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះមន្ត្រីរាជការ និងសប្បុរសជន ចំនួន ៧៩ រូប ៧២៩៤

## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ

២៥-៩-២០១២ -អនុក្រឹត្យលេខ ១៥៥ អនក្រ.បក ស្តីពី ការបង្កើតតំបន់គ្រប់គ្រង និង ការពារសត្វផ្សោតទន្លេមេគង្គ ៧២៩៦
២៦-៩-២០១២ -អនុក្រឹត្យលេខ ១៥៧ អនក្រ.បក ស្តីពី ការទទួលស្គាល់វិទ្យាស្ថានអាស៊ី កម្ពុជា ៧៣០៩
២៦-៩-២០១២ -អនុក្រឹត្យលេខ ១៥៨ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៧៣១២
២៧-៩-២០១២ -អនុក្រឹត្យលេខ ១៥៩ អនក្រ.បក ស្តីពី ការកាត់ចេញពីផែនទីគម្របព្រៃឈើ ឆ្នាំ ២០០២ និង ធ្វើអនុបយោគ មកជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីសរុបចំនួន ៥.៦៣១ ហិកតា នៅភូមិព្រៃទទឹង ឃុំឆ្នាល់មាន់ ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង និង ធ្វើប្រទានកម្មជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែង ៧៣១៤
២៦-៩-២០១២ -អនុក្រឹត្យលេខ ១២០៥ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយនគរបាលជាតិ ៧៣១៧
២៦-៩-២០១២ -អនុក្រឹត្យលេខ ១២០៦ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែង នាយនគរបាលជាតិ ៧៣១៨
២៧-៩-២០១២ -អនុក្រឹត្យលេខ ១២០៧ អនក្រ.តត ស្តីពី ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលនៃមន្ទីរពេទ្យកុមារជាតិ ៧៣១៩

# ព្រះរាជក្រម

នស/រកម/០៩១២/០០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញារ៉ូធើដាម ស្តីពីនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុនចំពោះសារធាតុគីមី និងថ្នាំកសិកម្មគ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១២ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១២ នាសម័យប្រជុំវិសាមញ្ញនីតិកាលទី៣ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុង អនុសញ្ញារ៉ូថឺដាម ស្តីពីនីតិវិធីនៃការយល់ព្រមផ្តល់ ព័ត៌មានជាមុនចំពោះសារធាតុគីមី និងថ្នាំកសិកម្ម គ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ

**មាត្រា ១.-**

អនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញារ៉ូថឺដាម ស្តីពីនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុន ចំពោះសារធាតុគីមីនិងថ្នាំកសិកម្មគ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ ដែលបានចុះហត្ថលេខានៅទីក្រុងរ៉ូថឺដាម នៃប្រទេសនីដឺឡែន នាថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩៨ និងបានចូលជាធរមាន នាថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៤ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នសរកម.១២០៩.០៤៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ហត្ថលេខា

ច័ន្ទ សារុន

លេខ: ៤០៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១២

អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

សយ សុខា

# អនុសញ្ញារ៉ូតឺដាម

ស្តីពី

# នីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុន ចំពោះសារធាតុគីមីនិងថ្នាំកសិកម្មគ្រោះថ្នាក់ ក្នុងពាណិជ្ជកម្មអន្តរជាតិ

អត្ថបទនិងឧបសម្ព័ន្ធ

(កែសម្រួលឡើងវិញក្នុងឆ្នាំ២០០៨)

# ROTTERDAM CONVENTION

**On the Prior Informed Consent Procedure For Certain Hazardous Chemicals And Pesticides in International Trade**

TEXT AND ANNEXES

(Revised in 2008)

## សេចក្តីផ្តើម

ការកើនឡើងក្នុងវិស័យពាណិជ្ជកម្មនិងផលិតកម្មសារធាតុគីមីក្នុងដំណាក់កាលបីទសវត្សចុងក្រោយនេះ បានធ្វើឱ្យមានកង្វល់យ៉ាងខ្លាំងទាំងក្នុងមជ្ឈដ្ឋានសាធារណៈនិងរដ្ឋអំពីសក្តានុពលនៃហានិភ័យដែលកើតឡើងដោយសារធាតុគីមីនិងថ្នាំកសិកម្មគ្រោះថ្នាក់។ ប្រទេសទាំងឡាយដែលខ្វះខាតនូវហេដ្ឋារចនាសម្ព័ន្ធក្នុងការតាមដានការនាំចូលនិងការប្រើប្រាស់សារធាតុគីមីទាំងនោះកំពុងតែទទួលរងគ្រោះថ្នាក់។

ឆ្លើយតបទៅនឹងកង្វល់ទាំងនោះ កម្មវិធីបរិស្ថានសហប្រជាជាតិ និងអង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ បានចាប់ផ្តើមធ្វើការអភិវឌ្ឍនិងបង្កើតនូវកម្មវិធីផ្លាស់ប្តូរព័ត៌មានដោយស្ម័គ្រចិត្តនាពាក់កណ្តាលទសវត្សឆ្នាំ១៩៨០។ អង្គការស្បៀងនិងកសិកម្មសហប្រជាជាតិបានដាក់ចុះនូវក្រមប្រតិបត្តិអន្តរជាតិរបស់ខ្លួនស្តីពីការចែកចាយនិងការប្រើប្រាស់ថ្នាំកសិកម្ម នាឆ្នាំ១៩៨៥ ហើយកម្មវិធីបរិស្ថានសហប្រជាជាតិបានបង្កើតឱ្យមានគោលការណ៍ណែនាំទីក្រុងឡុងដ៍សម្រាប់ការផ្លាស់ប្តូរព័ត៌មានចំពោះសារធាតុគីមីនៅក្នុងពាណិជ្ជកម្មអន្តរជាតិនាឆ្នាំ១៩៨៧។

នៅឆ្នាំ១៩៨៩ អង្គការទាំងពីរបានរួមគ្នាបង្កើតនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុន (Prior Informed Consent Procedure)។ ក្នុងការចូលរួមប្រតិបត្តិកម្មវិធីនេះ ដោយកម្មវិធីបរិស្ថានសហប្រជាជាតិ និងអង្គការស្បៀងនិងកសិកម្មសហប្រជាជាតិបានធ្វើឱ្យមានភាពប្រាកដថារដ្ឋាភិបាលទាំងអស់ទទួលបាននូវព័ត៌មានដែលគេត្រូវការអំពីសារធាតុគីមីគ្រោះថ្នាក់សម្រាប់វាយតម្លៃអំពីហានិភ័យ និងទទួលនូវព័ត៌មានសម្រេចចិត្ត មុននឹងធ្វើការនាំចូលសារធាតុគីមី។

ដោយមើលឃើញពីតម្រូវការអាណត្តិក្នុងការត្រួតពិនិត្យ មន្ត្រីដែលបានចូលរួមក្នុងកិច្ចប្រជុំកំពូលទីក្រុងរីយ៉ូឆ្នាំ១៩៩២ បានអនុម័តជំពូកទី១៩ នៃរបៀបវារៈទី២១ ដែលបានអំពាវនាវឱ្យមានការអនុម័តនូវឧបករណ៍គតិយុត្តដែលចងភ្ជាប់ទៅនឹងនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុន(PIC)នៅឆ្នាំ២០០០។ ដោយហេតុនេះ ក្រុមប្រឹក្សានៃអង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ(ក្នុងឆ្នាំ១៩៩៤) និងក្រុមប្រឹក្សាភិបាលនៃកម្មវិធីបរិស្ថានសហប្រជាជាតិ(ក្នុងឆ្នាំ១៩៩៥) បានប្រគល់អាណត្តិជាប្រធានប្រតិបត្តិដើម្បីចាប់ផ្តើមការចរចាដែលនាំទៅរកការបញ្ចប់អត្ថបទនៃអនុសញ្ញាស្តីពីនីតិវិធីក្នុងការផ្តល់ព័ត៌មានជាមុន សម្រាប់ការធ្វើពាណិជ្ជកម្មជាអន្តរជាតិនូវសារធាតុគីមីគ្រោះថ្នាក់នៅក្នុងខែមីនា ឆ្នាំ១៩៩៨។

អនុសញ្ញានេះត្រូវបានអនុម័តនិងបើកឱ្យមានការចុះហត្ថលេខានៅក្នុងសន្និសីទនៃតំណាងពេញសិទ្ធិរបស់បណ្តារដ្ឋនាទីក្រុងរ៉ូតើដាម នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៨ ហើយនឹងត្រូវចូលជាធរមាននៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៤។ សន្និសីទភាគីលើកទី១នៃអនុសញ្ញារ៉ូតើដាម(Cop-1) ដែលបានប្រព្រឹត្តទៅកាលពីខែកញ្ញា ឆ្នាំ២០០៤ បានឯកភាពដាក់បន្ថែមសារធាតុគីមីថ្មីចំនួន ១៤ ទៅក្នុងឧបសម្ពន្ធទីIII និងបានអនុម័តផ្នែកថ្មីមួយ(ឧបសម្ពន្ធទីVI) ស្តីពីមជ្ឈត្តកម្មនិងការសម្រុះសម្រួល។

កម្មវិធីបរិស្ថានសហប្រជាជាតិ និងអង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ បានរួមគ្នាបំពេញមុខងារលេខាធិការដ្ឋានសម្រាប់អនុសញ្ញារ៉ូតើដាម។ សម្រាប់ព័ត៌មានបន្ថែមអាចរកបាននៅគេហទំព័រ www.pic.int។

# អនុសញ្ញារ៉ូថឺដាមស្តីពី
# នីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុនចំពោះសារធាតុគីមី និងថ្នាំកសិកម្មគ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ

## ភាគីនៃអនុសញ្ញានេះ

ដោយយល់ដឹងពីគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរដល់សុខភាពមនុស្សនិងបរិស្ថានក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិនូវសារជាតុគីមីនិងថ្នាំកសិកម្មគ្រោះថ្នាក់។

ដោយចងចាំនូវបទប្បញ្ញត្តិពាក់ព័ន្ធសេចក្តីប្រកាសរីយ៉ូស្តីពីបរិស្ថាននិងការអភិវឌ្ឍព្រមទាំងជំពូកទី១៩នៃរបៀបវារៈទី២១ ស្តីពីការគ្រប់គ្រងបរិស្ថានលើសារជាតុគីមីពុលដែលរួមមានការទប់ស្កាត់ការជួញដូរជាអន្តរជាតិដោយខុសច្បាប់នូវផលិតផលពុលនិងមានគ្រោះថ្នាក់។

ដោយយកចិត្តទុកដាក់ពីការងារដែលធ្វើដោយកម្មវិធីសហប្រជាជាតិស្តីពីបរិស្ថាន និងអង្គការស្បៀងនិងកសិកម្មសហប្រជាជាតិក្នុងការប្រតិបត្តិដោយស្ម័គ្រចិត្តនូវនីតិវិធីផ្តល់ព័ត៌មានជាមុន ដូចបានកំណត់ក្នុងវិសោធនកម្មនៃគោលការណ៍ណែនាំក្រុងឡុងដ្រ៍ស្តីពីការផ្លាស់ប្តូរព័ត៌មានក្នុងពាណិជ្ជកម្មអន្តរជាតិសារជាតុគីមី (ដែលពីនេះទៅហៅថាវិសោធនកម្មគោលការណ៍ណែនាំក្រុងឡុងដ្រ៍) និងក្រមប្រតិបត្តិអន្តរជាតិដែលបង្កើតឡើងដោយអង្គការស្បៀងនិងកសិកម្មសហប្រជាជាតិស្តីពីការចែកចាយនិងការប្រើប្រាស់ថ្នាំកសិកម្ម(ដែលពីពេលនេះទៅហៅថាក្រមប្រតិបត្តិអន្តរជាតិ)។

ដោយយោងតាមកាលៈទេសៈនិងតម្រូវការចាំបាច់សម្រាប់ប្រទេសកំពុងអភិវឌ្ឍនិងប្រទេសដែលមានសេដ្ឋកិច្ចស្ថិតក្នុងអន្តរកាលជាពិសេសតម្រូវការក្នុងការពង្រឹងនូវសមត្ថភាពថ្នាក់ជាតិនិងសមត្ថភាពសម្រាប់គ្រប់គ្រងសារជាតុគីមី រួមមានការផ្ទេរបច្ចេកវិទ្យា ការផ្តល់ជំនួយហិរញ្ញវត្ថុនិងបច្ចេកទេស និងបង្កើននូវកិច្ចសហប្រតិបត្តិការរវាងភាគីទាំងអស់។

ដោយកត់សម្គាល់ឃើញថាតម្រូវការចំពោះមុខនៃប្រទេសមួយចំនួនសម្រាប់ព័ត៌មានស្តីពីការដឹកជញ្ជូនឆ្លងកាត់។

ដោយទទួលស្គាល់ថាកិច្ចប្រតិបត្តិគ្រប់គ្រងល្អចំពោះសារជាតុគីមីគួរតែត្រូវជំរុញឱ្យមាននៅគ្រប់ប្រទេស ដោយរាប់បញ្ចូលផងដែរនូវស្តង់ដាស្ម័គ្រចិត្តកំណត់ក្នុងក្រមប្រតិបត្តិអន្តរជាតិ និងក្រមសីលធម៌ក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិនូវសារជាតុគីមីរបស់ UNEP។

ក្នុងគោលបំណងធានាថាសារធាតុគីមីគ្រោះថ្នាក់ដែលនាំចេញពីដែនដីណាមួយត្រូវបាន វេចខ្ចប់និងបិទស្លាកសញ្ញាដែលមានលក្ខណៈការពារនូវសុខភាពមនុស្សនិងបរិស្ថាន ហើយមាន សង្គតិភាពជាមួយវិសោធនកម្មគោលការណ៍ណែនាំក្រុងឡុងដ្រ៍ និងក្រមប្រតិបត្តិអន្តរជាតិ។

ដោយទទួលស្គាល់ថា គោលនយោបាយពាណិជ្ជកម្មនិងបរិស្ថាន គួរតែត្រូវផ្តល់ទៅវិញ ទៅមកដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

ដោយឆ្លុះបញ្ចាំងឃើញថាគ្មានអ្វីនៅក្នុងអនុសញ្ញានេះត្រូវបានបកស្រាយថាជាការចាំបាច់ នៅក្នុងការផ្លាស់ប្តូរនូវសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីមួយនៅក្រោមកិច្ចព្រមព្រៀងអន្តរជាតិដែល មានស្រាប់អនុវត្តចំពោះសារធាតុគីមីក្នុងពាណិជ្ជកម្មអន្តរជាតិឬការការពារនូវបរិស្ថាន។

ដោយយល់ឃើញថា ការរៀបរាប់ខាងលើនេះមិនមានបំណងបង្កើតឱ្យមានឋានានុក្រម រវាងអនុសញ្ញានេះ និងកិច្ចព្រមព្រៀងជាអន្តរជាតិផ្សេងៗ។

ត្រូវបានកំណត់ការការពារនូវសុខភាពមនុស្ស រួមមានសុខភាពអ្នកប្រើប្រាស់ កម្មករ និងបរិស្ថានដែលប្រឆាំងទៅនឹងឥទ្ធិពលអាក្រក់បណ្តាលមកពីសារធាតុគីមីនិងថ្នាំកសិកម្មគ្រោះ ថ្នាក់នៅក្នុងពាណិជ្ជកម្មអន្តរជាតិ។

## បានព្រមព្រៀងដូចតទៅ៖

### មាត្រា ១.- គោលបំណង

គោលបំណងនៃអនុសញ្ញានេះគឺបង្កើននូវការចែករំលែកការទទួលខុសត្រូវ និងកិច្ចខិតខំសហប្រតិបត្តិការរវាងភាគីនៅក្នុងពាណិជ្ជកម្មអន្តរជាតិនូវសារធាតុគីមីគ្រោះថ្នាក់ ដើម្បីការពារនូវសុខភាពមនុស្សនិងបរិស្ថានពីការគំរាមកំហែងនិងរួមវិភាគទានចំពោះការប្រើប្រាស់ល្អនូវបរិស្ថាន ដោយសម្រួលការផ្លាស់ប្តូរនូវព័ត៌មានអំពីចរិតលក្ខណៈ ដោយផ្តល់នូវដំណើរការនៃការសម្រេចចិត្តថ្នាក់ជាតិនៅក្នុងការនាំចូលនាំចេញ និងដោយការផ្សព្វផ្សាយពីការសម្រេចចិត្តនេះដល់រាល់បណ្តាភាគី។

### មាត្រា ២.- និយមន័យ

សម្រាប់គោលបំណងនៃអនុសញ្ញានេះ៖

ក- **សារធាតុគីមី**(Chemical)៖ មានន័យថាជាសារធាតុមួយមុខ ឬជាសារធាតុលាយផ្សំ ឬបានមកពីធម្មជាតិ ប៉ុន្តែមិនរួមបញ្ចូលនូវសរីរាង្គរស់(Living organism)។ សារធាតុគីមីរួមមានប្រភេទ៖ ថ្នាំកសិកម្ម(រួមទាំងផលិតផលថ្នាំកសិកម្មលាយផ្សំគ្រោះថ្នាក់ខ្ពស់) និងសារធាតុគីមីឧស្សាហកម្ម។

ខ- **សារធាតុគីមីហាមឃាត់**(Banned Chemical)៖ មានន័យថាជាសារធាតុគីមីដែលការប្រើប្រាស់ទាំងអស់នៅក្នុងប្រភេទមួយឬច្រើន ត្រូវបានហាមឃាត់ដោយវិធានការច្បាប់ចុងក្រោយ ដើម្បីការពារសុខភាពមនុស្សនិងបរិស្ថាន។ សារធាតុគីមីហាមឃាត់នេះរួមបញ្ចូលទាំងសារធាតុគីមីដែលត្រូវបដិសេធការប្រើប្រាស់តាំងពីដំបូង ឬត្រូវបានប្រមូលមកវិញដោយរោងចក្រនិងពីទីផ្សារក្នុងស្រុក ឬពីដំណើរការពិចារណាយល់ព្រមនៅក្នុងស្រុក និងនៅពេលដែលមានភស្តុតាងបញ្ជាក់ច្បាស់ថាសកម្មភាពទាំងនេះធ្វើឡើងដើម្បីការពារនូវសុខភាពមនុស្សឬបរិស្ថាន។

គ- **សារធាតុគីមីស្ថិតក្រោមលក្ខខណ្ឌខ្ពស់**(Severely Restricted Chemical)៖ មានន័យថាជាសារធាតុគីមីដែលការប្រើប្រាស់ស្ទើរតែទាំងអស់នៅក្នុងប្រភេទមួយឬច្រើន ត្រូវបានហាមឃាត់ដោយវិធានការច្បាប់ចុងក្រោយ ដើម្បីការពារនូវសុខភាពមនុស្សឬបរិស្ថាន ប៉ុន្តែត្រូវបានអនុញ្ញាតសម្រាប់ការប្រើប្រាស់ជាក់លាក់ណាមួយ។ សារធាតុគីមីទាំងនេះរួមមានសារធាតុគីមីណាមួយដែលការប្រើប្រាស់ស្ទើរតែទាំងអស់ធ្លាប់ បានបដិសេធក្នុងការអនុញ្ញាតឬធ្លាប់បានប្រមូលយកវិញដោយរោងចក្រ និងពីទីផ្សារក្នុងស្រុក ឬពីដំណើរការពិចារណាយល់ព្រមនៅក្នុងស្រុក និងនៅពេលដែលមានភស្តុតាងបញ្ជាក់ច្បាស់ថាសកម្មភាពទាំងនេះធ្វើឡើងដើម្បីការពារនូវសុខភាពមនុស្សឬបរិស្ថាន។

**ឃ- ផលិតផលថ្នាំកសិកម្មលាយផ្សំមានគ្រោះថ្នាក់ខ្ពស់**(Severely Hazardous Pesticides Formulation)៖ មានន័យថាជាសារធាតុគីមីដែលបានលាយផ្សំសម្រាប់ប្រើជាថ្នាំកសិកម្ម (Pesticidal use)ដែលធ្វើឱ្យប៉ះពាល់សុខភាពឬបរិស្ថាន តាមការសង្កេតឃើញក្នុងដំណាក់កាលខ្លីមួយបន្ទាប់ពីការប្រឈមមួយលើកឬច្រើនលើកក្រោមលក្ខខណ្ឌនៃការប្រើប្រាស់។

**ង- វិធានការច្បាប់ចុងក្រោយ** (Final regulatory action)៖ មានន័យថាវិធានការច្បាប់ចុងក្រោយបង្អស់ដែលអនុវត្តដោយភាគីនោះ ក្នុងគោលបំណងហាមឃាត់ឬដាក់លក្ខខណ្ឌចំពោះសារធាតុគីមីណាមួយ។

**ច- ការនាំចេញនិងការនាំចូល**(Export and Import)៖ មានន័យថានៅក្នុងបរិបទនេះ គឺជាការផ្លាស់ទីសារធាតុគីមីពីប្រទេសមួយទៅប្រទេសមួយ ប៉ុន្តែមិនរួមបញ្ចូលនូវប្រតិបត្តិការឆ្លងកាត់ឡើយ។

**ឆ- ភាគី**(Party)៖ មានន័យថាជារដ្ឋមួយឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ដែលយល់ព្រមចងសម្ពន្ធទៅនឹងអនុសញ្ញានេះ និងយល់ព្រមអនុវត្តនូវអនុសញ្ញានេះ។

**ជ- អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់** (Regional Economic Integration Organization)៖ មានន័យថាជាអង្គការមួយដែលរួមបង្កើតដោយរដ្ឋអធិបតេយ្យទាំងឡាយនៃតំបន់ណាមួយដែលរដ្ឋជាសមាជិកទាំងអស់បានផ្ទេរនូវសមត្ថកិច្ចទាក់ទិននឹងបញ្ហាគ្រប់គ្រងដោយអនុសញ្ញានេះ និងដែលមានអំណាចត្រឹមត្រូវដោយអនុលោមតាមនីតិវិធីផ្ទៃក្នុង ដើម្បីចុះហត្ថលេខាផ្តល់សច្ចាប័ន ទទួលយក យល់ព្រម ឬការចូលជាភាគីនៃអនុសញ្ញានេះ។

**ឈ-គណៈកម្មាធិការត្រួតពិនិត្យសារធាតុគីមី** (Chemical Review Committee)៖ សំដៅដល់អង្គភាពចំណុះក្រោមអនុសញ្ញាដែលមានចែងនៅក្នុងកថាខណ្ឌទី៦ មាត្រា១៨ នៃអនុសញ្ញានេះ។

## មាត្រា ៣.- វិសាលភាពនៃអនុសញ្ញា

១- អនុសញ្ញានេះគ្របដណ្តប់លើ៖

ក- សារធាតុគីមីហាមឃាត់ឬស្ថិតក្រោមលក្ខខណ្ឌខ្ពស់

ខ- ផលិតផលថ្នាំកសិកម្មលាយផ្សំមានគ្រោះថ្នាក់ខ្ពស់

២- អនុសញ្ញានេះមិនគ្របដណ្តប់លើ៖

ក- ថ្នាំញៀនឬសារធាតុធ្វើឱ្យវង្វេងស្មារតី (Psychotropic)

ខ- ជាតុវិទ្យុសកម្ម

គ- កាកសំណល់

ឃ-អាវុធគីមី

ង- ឱសថរួមមានឱសថមនុស្សនិងបសុឱសថ

ច- សារធាតុគីមីដែលប្រើដូចជាចំណីបន្ថែម

ឆ- ម្ហូបអាហារ

ជ- សារធាតុគីមីដែលបរិមាណតិចតួចមិនមានផលប៉ះពាល់លើសុខភាពមនុស្ស ឬបរិស្ថានដែលនាំចូលៈ

(i)- សម្រាប់គោលបំណងស្រាវជ្រាវឬវិភាគ

(ii)-ដោយឯកជនសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនក្នុងបរិមាណដែលសមស្របសម្រាប់ប្រើប្រាស់។

## មាត្រា ៤.- អាជ្ញាធរជាតិ

១- ភាគីនីមួយៗត្រូវចាត់តាំងនូវអាជ្ញាធរជាតិមួយឬច្រើន ដែលនឹងត្រូវផ្តល់សិទ្ធិអំណាចបំពេញភារកិច្ចជាតំណាងក្នុងមុខងាររដ្ឋបាលតាមតម្រូវការរបស់អនុសញ្ញានេះ។

២- ភាគីនីមួយៗត្រូវអះអាងឱ្យប្រាកដថាអាជ្ញាធរទាំងនោះមានធនធានគ្រប់គ្រាន់ក្នុងដំណើរការការងារប្រកបដោយប្រសិទ្ធភាព។

៣- ភាគីនីមួយៗត្រូវជូនដំណឹងអំពីឈ្មោះនិងអាសយដ្ឋានអាជ្ញាធរមកលេខាធិការដ្ឋានឱ្យបានមុនថ្ងៃដែលអនុសញ្ញាត្រូវបានចូលជាធរមាន។ ហើយត្រូវជូនដំណឹងជាមុននូវរាល់ការផ្លាស់ប្តូរឈ្មោះនិងអាសយដ្ឋានរបស់អាជ្ញាធរទាំងនោះ។

៤- លេខាធិការដ្ឋានត្រូវផ្តល់ព័ត៌មានភ្លាមៗជូនភាគីនូវការជូនដំណឹងដែលខ្លួនបានទទួលក្រោមកថាខណ្ឌទី៣ នៃមាត្រានេះ។

## មាត្រា ៥.- នីតិវិធីសម្រាប់សារធាតុគីមីហាមឃាត់និងសារធាតុគីមីស្ថិតក្រោមលក្ខខណ្ឌខ្ពស់

១- ភាគីនីមួយៗដែលបានអនុម័តយល់ព្រមនូវវិធានការច្បាប់ចុងក្រោយ ត្រូវឱ្យដំណឹងជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋានពីវិធានការទាំងនេះ។ ការឱ្យដំណឹងជាលាយលក្ខណ៍អក្សរត្រូវធ្វើយ៉ាងឆាប់បំផុតតាមដែលអាចធ្វើទៅបានដោយមិនឱ្យហួសពី៩០(កៅសិប)ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានចាត់វិធានការច្បាប់ចុងក្រោយ ហើយត្រូវរួមបញ្ចូលនូវព័ត៌មានដែលតម្រូវឱ្យមាននៅក្នុងឧបសម្ពន្ធទី I ប្រសិនបើចាំបាច់។

២- ភាគីនីមួយៗនៅថ្ងៃដែលអនុសញ្ញានេះត្រូវបានចូលជាធរមាន ត្រូវឱ្យដំណឹងជាលាយលក្ខណ៍អក្សរអំពីប្រសិទ្ធភាពនៃវិធានការច្បាប់ចុងក្រោយជាបន្ទាន់ភ្លាម លើកលែងតែភាគីដែលបានជូនដំណឹងនូវវិធានការច្បាប់ចុងក្រោយជាលាយលក្ខណ៍

អក្សរក្រោមវិសោធនកម្មគោលការណ៍ណែនាំក្រុងឡុងដ្រ៍ ឬក្រមប្រតិបត្តិអន្តរជាតិ ដោយពុំចាំបាច់ផ្តល់ដំណឹងនោះម្តងទៀត។

៣- យ៉ាងឆាប់បំផុតមិនឱ្យលើសពី០៦(ប្រាំមួយ)ខែ បន្ទាប់ពីបានទទួលការជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងកថាខណ្ឌទី១ និង២នៃមាត្រានេះ លេខាធិការដ្ឋានត្រូវត្រួតពិនិត្យមើលថាតើការជូនដំណឹងជាលាយលក្ខអក្សរនោះរួមមានព័ត៌មានដែលតម្រូវឱ្យមានតាមឧបសម្ព័ន្ធទី I ហើយឬនៅ។ ប្រសិនបើការជូនដំណឹងនោះមានព័ត៌មានគ្រប់គ្រាន់ហើយ លេខាធិការដ្ឋានត្រូវបញ្ជូនបន្តភ្លាមទៅគ្រប់ភាគីនូវព័ត៌មានដែលបានទទួលនោះដោយសង្ខេប។ ប្រសិនបើការជូនដំណឹងជាលាយលក្ខណ៍អក្សរពុំមានព័ត៌មានគ្រប់គ្រាន់ទេ ត្រូវជូនដំណឹងទៅភាគីដែលជូនដំណឹងនោះវិញ។

៤- នៅរៀងរាល់០៦(ប្រាំមួយ)ខែ លេខាធិការដ្ឋានត្រូវបញ្ជូនទៅគ្រប់ភាគីនូវព័ត៌មានសង្ខេបដែលទទួលបាន ដោយអនុលោមទៅតាមកថាខណ្ឌទី១ និងទី២ នៃមាត្រានេះរួមមានព័ត៌មានដែលទាក់ទងនឹងការជូនដំណឹងជាលាយលក្ខណ៍អក្សរដែលមិនបានបញ្ចូលព័ត៌មានគ្រប់គ្រាន់ដែលតម្រូវឱ្យមាននៅក្នុងឧបសម្ព័ន្ធទី I។

៥- នៅពេលដែលលេខាធិការដ្ឋានបានទទួលនូវការជូនដំណឹងជាលាយលក្ខណ៍អក្សរយ៉ាងតិចមួយពីតំបន់ពីរផ្សេងគ្នានៃការយល់ព្រមផ្តល់ព័ត៌មានជាមុនចំពោះសារធាតុគីមីពិសេសណាមួយដែលត្រូវបានពិនិត្យឃើញថាទាក់ទងទៅនឹងតម្រូវការនៅក្នុងឧបសម្ព័ន្ធទី I ត្រូវបញ្ជូនទៅគណៈកម្មាធិការត្រួតពិនិត្យសារធាតុគីមី។ សមាសភាពរបស់តំបន់នៃការយល់ព្រមផ្តល់ព័ត៌មានជាមុន ត្រូវបានកំណត់នៅក្នុងសេចក្តីសម្រេចដែលត្រូវបានអនុម័តជាឯកច្ឆន្ទនៅក្នុងកិច្ចប្រជុំសន្និបាតលើកទី១ រវាងភាគីទាំងអស់។

៦- គណៈកម្មាធិការត្រួតពិនិត្យសារធាតុគីមីត្រូវពិនិត្យឡើងវិញនូវព័ត៌មានដែលបានផ្តល់នៅក្នុងការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយអនុលោមតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធទីII នឹងត្រូវផ្តល់អនុសាសន៍ដល់សន្និបាតនៃភាគីនូវសារធាតុគីមីជាបញ្ហាដែលគួរធ្វើជាកម្មវត្ថុចំពោះនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុន និងគួរត្រូវបានដាក់បញ្ចូលក្នុងបញ្ជីនៃឧបសម្ព័ន្ធទីIIIឬទេ។

**មាត្រា ៦.- វិធានសម្រាប់ផលិតផលថ្នាំកសិកម្មលាយផ្សំមានគ្រោះថ្នាក់ខ្ពស់**

១- ភាគីដែលជាប្រទេសកំពុងអភិវឌ្ឍ ឬប្រទេសដែលមានសេដ្ឋកិច្ចស្ថិតក្នុងអន្តរកាលហើយដែលកំពុងប្រឈមមុខនឹងបញ្ហាទាក់ទងនឹងផលិតផលថ្នាំកសិកម្មលាយផ្សំគ្រោះថ្នាក់ខ្ពស់ ដែលស្ថិតនៅក្នុងលក្ខខណ្ឌនៃការប្រើប្រាស់នៅក្នុងទឹកដីរបស់ខ្លួន

អាចស្នើសុំមកលេខាធិការដ្ឋានដើម្បីចាត់បញ្ចូលថ្នាំកសិកម្មគ្រោះថ្នាក់ខ្លាំងនៅក្នុងឧបសម្ព័ន្ធទីIII។ នៅក្នុងការលើកសំណើ ភាគីអាចប្រើប្រាស់ព័ត៌មានបច្ចេកទេសពីប្រភពណាមួយក៏បាន។ គម្រោងសំណើត្រូវបញ្ចូលនូវព័ត៌មានដូចបានកំណត់ក្នុងផ្នែកទី១ នៃឧបសម្ព័ន្ធទីIV។

២- ទោះជាស្ថិតក្នុងសភាពការណ៍ណាក៏ដោយ ក្នុងរយៈពេលមិនលើសពី០៦(ប្រាំមួយ)ខែ បន្ទាប់ពីការទទួលបាននូវសំណើក្នុងកថាខណ្ឌទី១ លេខាធិការដ្ឋានត្រូវប្រញាប់ផ្ទៀងផ្ទាត់សំណើនោះជាមួយតម្រូវការព័ត៌មានគ្រប់គ្រាន់តាមការកំណត់ក្នុងផ្នែកទី១ នៃឧបសម្ព័ន្ធទីIV។ ប្រសិនបើសំណើនោះមានព័ត៌មានគ្រប់គ្រាន់ហើយ លេខាធិការដ្ឋានត្រូវបញ្ជូនបន្តភ្លាមទៅគ្រប់ភាគីនូវព័ត៌មានដែលបានទទួលនោះដោយសង្ខេប។ ប្រសិនបើសំណើពុំមានព័ត៌មានគ្រប់គ្រាន់ទេត្រូវជូនដំណឹងទៅភាគីស្នើនោះវិញ។

៣- លេខាធិការដ្ឋានត្រូវប្រមូលនូវព័ត៌មានបន្ថែមដែលបានកំណត់នៅក្នុងផ្នែកទី២ នៃឧបសម្ព័ន្ធទីIV ចំពោះគម្រោងសំណើដែលបានផ្ញើមកក្រោមកថាខណ្ឌទី២។

៤- នៅពេលដែលតម្រូវការនៃកថាខណ្ឌទី២ និងទី៣ខាងលើត្រូវបានបំពេញហើយទាក់ទងនឹងផលិតផលថ្នាំកសិកម្មលាយផ្សំគ្រោះថ្នាក់ខ្ពស់ លេខាធិការដ្ឋានត្រូវបញ្ជូនបន្តនូវសំណើនិងព័ត៌មានពាក់ព័ន្ធទៅគណៈកម្មការត្រួតពិនិត្យសារធាតុគីមី។

៥- គណៈកម្មការត្រួតពិនិត្យសារធាតុគីមី ត្រូវពិនិត្យឡើងវិញនូវព័ត៌មានដែលបានផ្តល់នៅក្នុងសំណើនិងព័ត៌មានបន្ថែមដែលប្រមូលបាន ដោយអនុលោមតាមលក្ខណវិនិច្ឆ័យដែលបានកំណត់នៅក្នុងផ្នែកទី៣នៃឧបសម្ព័ន្ធទីIV ហើយត្រូវផ្តល់អនុសាសន៍ចំពោះសន្និបាតភាគីថារូបមន្តថ្នាំកសិកម្មគ្រោះថ្នាក់ខ្លាំងជាបញ្ហានេះគួរត្រូវបានចាត់ទុកជាកម្មវត្ថុស្ថិតនៅក្នុងនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុន និងត្រូវចាត់បញ្ចូលក្នុងបញ្ជីនៃឧបសម្ព័ន្ធទីIII។

**មាត្រា ៧.- បញ្ជីឈ្មោះសារធាតុគីមីនៅក្នុងឧបសម្ព័ន្ធទីIII**

១- ចំពោះសារធាតុគីមីនីមួយៗដែលគណៈកម្មការត្រួតពិនិត្យសារធាតុគីមីបានសម្រេចផ្តល់អនុសាសន៍ចាត់បញ្ចូលទៅក្នុងបញ្ជីឈ្មោះនៃឧបសម្ព័ន្ធទីIII ត្រូវរៀបចំជាឯកសារណែនាំនៃសេចក្តីព្រាងសេចក្តីសម្រេច(draft decision guidance document)។ ឯកសារណែនាំនៃសេចក្តីសម្រេចនេះយ៉ាងហោចណាស់ត្រូវឈរលើព័ត៌មានដែលកំណត់នៅក្នុងឧបសម្ព័ន្ធទីI ឬក៏អាចមាននៅក្នុងឧបសម្ព័ន្ធទីIV និងរួមបញ្ចូលនូវព័ត៌មានទាក់ទងនឹងការប្រើប្រាស់សារធាតុគីមីក្នុងចំណាត់ថ្នាក់ណាមួយ ក្រៅពីចំណាត់ថ្នាក់ដែលត្រូវចាត់វិធានការច្បាប់ចុងក្រោយ។

២- អនុសាសន៍ដែលយោងនៅក្នុងកថាខណ្ឌទី១ និងឯកសារណែនាំនៃសេចក្តីសម្រេច ត្រូវបញ្ជូនបន្តដាក់ក្នុងសន្និបាតភាគី។ សន្និបាតភាគីត្រូវសម្រេចថាសារធាតុគីមីនោះ ត្រូវចាត់ទុកជាកម្មវត្ថុស្ថិតនៅក្នុងនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុន និងចុះបញ្ជីឈ្មោះសារធាតុគីមីនោះនៅក្នុងឧបសម្ពន្ធទីIII និងយល់ព្រមលើឯកសារណែនាំនៃសេចក្តីព្រាងសេចក្តីសម្រេច។

៣- នៅពេលការសម្រេចចុះបញ្ជីសារធាតុគីមីមួយក្នុងបញ្ជីនៃឧបសម្ពន្ធទីIII ត្រូវបានទទួលយកនិងឯកសារណែនាំនៃសេចក្តីសម្រេចដែលពាក់ព័ន្ធ ត្រូវបានយល់ព្រមដោយភាគីទាំងអស់ លេខាធិការដ្ឋានត្រូវជូនដំណឹងពីព័ត៌មាននេះទៅគ្រប់ភាគីបន្ទាន់។

## មាត្រា ៨.- សារធាតុគីមីដែលស្ថិតនៅក្នុងនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុនដោយស្ម័គ្រចិត្ត

សម្រាប់សារធាតុគីមីក្រៅអំពីសារធាតុគីមីដែលស្ថិតនៅក្នុងបញ្ជីឈ្មោះឧបសម្ពន្ធទីIII ដែលត្រូវបានចាត់ទុកជាសារធាតុគីមីស្ថិតនៅក្នុងនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុនដោយស្ម័គ្រចិត្តមុនថ្ងៃសន្និបាតលើកដំបូងរវាងភាគីទាំងអស់ សន្និបាតភាគីទាំងអស់ត្រូវសម្រេចនៅក្នុងកិច្ចប្រជុំនេះដើម្បីចុះឈ្មោះសារធាតុគីមីទាំងនោះនៅក្នុងបញ្ជីនៃឧបសម្ពន្ធទីIII ក្នុងករណីបានបំពេញតម្រូវការគ្រប់គ្រាន់ក្នុងការចុះបញ្ជីនេះ។

## មាត្រា ៩.- ការដកចេញនូវសារធាតុគីមីពីឧបសម្ពន្ធទី III

១- ប្រសិនបើភាគីមួយផ្តល់ជូនលេខាធិការដ្ឋាននូវព័ត៌មានដែលមិនទាន់មានបាននៅក្នុងពេលសម្រេចអំពីបញ្ជីឈ្មោះសារធាតុគីមីនៅក្នុងឧបសម្ពន្ធទីIII និងព័ត៌មាននោះបញ្ជាក់ថាការចុះបញ្ជីសារធាតុគីមីនោះមិនអាចត្រូវបានវិនិច្ឆ័យតទៅទៀតដោយអនុលោមតាមលក្ខណវិនិច្ឆ័យកំណត់ក្នុងឧបសម្ពន្ធទីII ឬជាករណីដែលអាចនៅក្នុងឧបសម្ពន្ធទីIV លេខាធិការដ្ឋានត្រូវបញ្ជូនបន្តនូវព័ត៌មាននោះទៅគណៈកម្មការត្រួតពិនិត្យសារធាតុគីមី។

២- គណៈកម្មការត្រួតពិនិត្យសារធាតុគីមីត្រូវពិនិត្យឡើងវិញនូវព័ត៌មានដែលបានទទួលក្រោមកថាខណ្ឌទី១។ សម្រាប់សារធាតុគីមីនីមួយៗដែលគណៈកម្មការត្រួតពិនិត្យសារធាតុគីមីធ្វើការសម្រេច ដោយអនុលោមតាមលក្ខណវិនិច្ឆ័យកំណត់នៅក្នុងឧបសម្ពន្ធទីII ឬជាករណីដែលអាចនៅក្នុងឧបសម្ពន្ធទីIV ត្រូវផ្តល់

អនុសាសន៍ចំពោះការដកចេញពីឧបសម្ពន្ធទីIII ហើយត្រូវរៀបចំសេចក្តីព្រាងកែសម្រួលឯកសារណែនាំនៃសេចក្តីសម្រេច។

៣- អនុសាសន៍ដូចក្នុងកថាខណ្ឌទី២ ត្រូវបញ្ជូនទៅសន្និបាតភាគីដោយភ្ជាប់ជាមួយនូវឯកសារណែនាំនៃការព្រាងសេចក្តីសម្រេចដែលបានកែសម្រួលឡើងវិញ។ សន្និបាតភាគីត្រូវសម្រេចថាសារធាតុគីមីនឹងត្រូវដកចេញពីឧសម្ពន្ធទីIII និងត្រូវយល់ព្រមលើឯកសារណែនាំនៃការព្រាងកែសម្រួលសេចក្តីសម្រេចនោះ។

៤- នៅពេលការសម្រេចដកចេញសារធាតុគីមីណាមួយពីឧបសម្ពន្ធទីIII ត្រូវបានទទួលយកនិងឯកសារណែនាំនៃការព្រាងកែសម្រួលសេចក្តីសម្រេច ត្រូវបានយល់ព្រមដោយសន្និបាតភាគី លេខាធិការដ្ឋានត្រូវបញ្ជូនព័ត៌មានជាបន្ទាន់ទៅគ្រប់ភាគីទាំងអស់។

**មាត្រា ១០.- កាតព្វកិច្ចពាក់ព័ន្ធនឹងការនាំចូលសារធាតុគីមីក្នុងឧបសម្ពន្ធទីIII**

១- ភាគីនីមួយៗត្រូវអនុវត្តន៍វិធានការច្បាប់ឬវិធានការរដ្ឋបាលឱ្យបានសមស្របបំផុតដើម្បីធានាអះអាងចំពោះការនាំចូលសារធាតុគីមីដែលមានក្នុងឧបសម្ពន្ធទីIII។

២- ភាគីនីមួយៗត្រូវបញ្ជូនទៅលេខាធិការដ្ឋានឱ្យបានឆាប់និងមិនឱ្យយឺតជាងរយៈពេល៩ខែក្រោយកាលបរិច្ឆេទនៃការបញ្ជូនឯកសារណែនាំនៃសេចក្តីសម្រេចដូចបានកំណត់ក្នុងកថាខណ្ឌទី៣នៃមាត្រា៧នូវការឆ្លើយតបអំពីការនាំចូលសារធាតុគីមីដែលពាក់ព័ន្ធនាពេលអនាគត។ ប្រសិនបើភាគីមួយមានការកែប្រែនូវការឆ្លើយតបនោះត្រូវផ្តល់នូវការឆ្លើយតបដែលបានកែប្រែជាបន្ទាន់ទៅអគ្គលេខាធិការដ្ឋាន។

៣- នៅពេលផុតរយៈពេលកំណត់ក្នុងកថាខណ្ឌទី២នៃមាត្រានេះ លេខាធិការដ្ឋានត្រូវបញ្ជូនជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅភាគីដែលមិនបានផ្តល់ការឆ្លើយតបបែបនេះដើម្បីធ្វើការឆ្លើយតប។ ភាគីដែលពុំមានលទ្ធភាពផ្តល់ការឆ្លើយតប លេខាធិការដ្ឋានត្រូវជួយគេក្នុងការផ្តល់នូវការឆ្លើយតបនៅក្នុងពេលវេលាមួយដូចបានបញ្ជាក់ក្នុងប្រយោគចុងក្រោយនៃកថាខណ្ឌទី២ នៃមាត្រា១១។

៤- ការឆ្លើយតបក្រោមកថាខណ្ឌទី២ ត្រូវមាន៖

ក-សេចក្តីសម្រេចចុងក្រោយអនុលោមទៅតាមវិធានការច្បាប់និងវិធានការរដ្ឋបាល៖

ក១- យល់ព្រមឱ្យនាំចូល

ក២- មិនយល់ព្រមឱ្យនាំចូល

ក៣- យល់ព្រមឱ្យមានការនាំចូលតែអ្វីដែលមានចែងក្នុងលក្ខខណ្ឌ។

ខ-ការឆ្លើយតបបណ្តោះអាសន្នរួមមាន៖

ខ១- សេចក្តីសម្រេចបណ្តោះអាសន្នដែលយល់ព្រមឱ្យនាំចូលដោយមានឬគ្មានលក្ខខណ្ឌបញ្ជាក់ ឬមិនយល់ព្រមឱ្យនាំចូលក្នុងរយៈពេលបណ្តោះអាសន្ន។

ខ២- សេចក្តីថ្លែងការណ៍ដែលបញ្ជាក់ថាសេចក្តីសម្រេចចុងក្រោយកំពុងស្ថិតក្រោមការពិចារណាយ៉ាងសកម្ម។

ខ៣- សំណូមពរចំពោះលេខាធិការដ្ឋាន ឬភាគីដែលបានជូនដំណឹងនូវវិធានការច្បាប់ចុងក្រោយដើម្បីផ្តល់ព័ត៌មានបន្ថែម។

ខ៤- សំណូមពរចំពោះលេខាធិការដ្ឋាននូវជំនួយការបច្ចេកទេសសម្រាប់ការវាយតម្លៃសារធាតុគីមី។

៥- ការឆ្លើយតបក្នុងអនុកថាខណ្ឌ(ក)ឬ(ខ)នៃកថាខណ្ឌទី៤ ត្រូវទាក់ទងតែទៅនឹងប្រភេទសារធាតុគីមីក្នុងឧបសម្ពន្ធទីIIIប៉ុណ្ណោះ។

៦- សេចក្តីសម្រេចចុងក្រោយត្រូវភ្ជាប់នូវសេចក្តីអធិប្បាយវិធានការរដ្ឋបាលនិងច្បាប់ណាមួយដែលបានយោង។

៧- ភាគីនីមួយៗត្រូវបញ្ជូនទៅលេខាធិការដ្ឋាននូវការឆ្លើយតបចំពោះសារធាតុគីមីនីមួយៗដែលបានចុះបញ្ជីក្នុងឧបសម្ពន្ធទីIII មិនឱ្យយឺតជាងកាលបរិច្ឆេទនៃការចូលជាធរមាននៃអនុសញ្ញានេះ។ ភាគីណាមួយដែលបានផ្តល់នូវការឆ្លើយតបរួចហើយក្រោមវិសោធនកម្មនៃគោលការណ៍ណែនាំក្រុងឡុងដ្រ៍ ឬក្រមប្រតិបត្តិអន្តរជាតិ មិនចាំបាច់បញ្ជូនវិញនូវការឆ្លើយតបទាំងនោះទេ។

៨- ភាគីនីមួយៗត្រូវធ្វើការឆ្លើយតបក្រោមមាត្រានេះនូវអ្វីដែលពាក់ព័ន្ធស្ថិតក្នុងយុត្តាធិការរបស់ខ្លួន ដោយអនុលោមតាមវិធានការច្បាប់និងរដ្ឋបាលរបស់ខ្លួន។

៩- អនុលោមទៅតាមកថាខណ្ឌទី២ និងទី៤ខាងលើ និងកថាខណ្ឌទី២នៃមាត្រា១១ ភាគីណាមួយដែលយកការសម្រេចមួយដែលមិនយល់ព្រមចំពោះការនាំចូលសារធាតុគីមីណាមួយ ឬយល់ព្រមចំពោះការនាំចូលរបស់ខ្លួនក្រោមលក្ខខណ្ឌជាក់លាក់ ឬប្រសិនបើមិនទាន់យកការសម្រេចណាមួយនៅឡើយ ត្រូវហាមឃាត់ព្រមៗគ្នា ឬបង្កើតកម្មវត្ថុចំពោះលក្ខខណ្ឌដូចគ្នាសម្រាប់៖

ក- ការនាំចូលសារធាតុគីមីនោះពីប្រភពណាក៏ដោយ។

ខ- ផលិតកម្មសារធាតុគីមីសម្រាប់ប្រើប្រាស់ក្នុងស្រុក។

១០-ជារៀងរាល់៦ខែម្តង លេខាធិការដ្ឋានត្រូវជូនព័ត៌មានដល់គ្រប់ភាគីទាំងអស់អំពីការឆ្លើយតបដែលទទួលបាន។ ព័ត៌មាននេះត្រូវរួមបញ្ចូលនូវការអធិប្បាយពីវិធានការច្បាប់និងរដ្ឋបាលដែលសេចក្តីសម្រេចត្រូវបានយោង។ បន្ថែមលើនេះលេខាធិ

ការដ្ឋានត្រូវជូនព័ត៌មានដល់ភាគីទាំងអស់នូវករណីខកខានណាមួយនៃការបញ្ជូនការឆ្លើយតបនីមួយៗ។

**មាត្រា ១១.- ភាតព្វកិច្ចដែលពាក់ព័ន្ធនឹងការនាំចេញសារធាតុគីមីក្នុងឧសម្ព័ន្ធទីIII**

១- ភាគីដែលនាំចេញសារធាតុគីមីនីមួយៗត្រូវ៖

ក-អនុវត្តវិធានការច្បាប់និងរដ្ឋបាលសមស្រប ដើម្បីធ្វើទំនាក់ទំនងចាត់ចែងការឆ្លើយតបដែលត្រូវបានបញ្ជូនដោយលេខាធិការដ្ឋាន អនុលោមតាមកថាខណ្ឌទី១០នៃមាត្រា១០ ចំពោះទៅគ្រប់ស្ថាប័នពាក់ព័ន្ធនៅក្នុងយុត្តាធិការរបស់ខ្លួន។

ខ-ចាត់វិធានការច្បាប់និងរដ្ឋបាលសមស្រប ដើម្បីធានាថាអ្នកនាំចេញក្នុងយុត្តាធិការរបស់ខ្លួនអនុវត្តតាមបណ្តាសេចក្តីសម្រេចក្នុងការឆ្លើយតបនីមួយៗមិនឲ្យយឺតជាង៦ខែក្រោយកាលបរិច្ឆេទដែលលេខាធិការដ្ឋានជូនដំណឹងជាលើកដំបូងទៅបណ្តាភាគីអំពីការឆ្លើយតបនោះអនុលោមតាមកថាខណ្ឌទី១០នៃមាត្រា១០។

គ-ផ្តល់ការណែនាំនិងជួយដល់ភាគីនាំចូលសារធាតុគីមីដោយផ្អែកតាមសំណើជាក់ស្តែង៖

គ១- ទទួលព័ត៌មានបន្ថែមដើម្បីជួយពួកគេចាត់វិធានការតាមកថាខណ្ឌទី៤ នៃមាត្រា១០ និងកថាខណ្ឌទី២(គ)ខាងក្រោម។

គ២- ពង្រឹងសមត្ថភាពនិងលទ្ធភាពរបស់ពួកគេក្នុងការគ្រប់គ្រងសារធាតុគីមីប្រកបដោយសុវត្ថិភាពក្នុងវដ្តនៃផលិតផល។

២- ភាគីនីមួយៗត្រូវធានាថាសារធាតុគីមីក្នុងឧបសម្ព័ន្ធទីIII មិនត្រូវបាននាំចេញពីទឹកដីរបស់ខ្លួនទៅភាគីនាំចូលណាមួយដែលខកខានក្នុងការឆ្លើយតប ឬបានបញ្ជូនការឆ្លើយតបបណ្តោះអាសន្នដែលមិនមានការសម្រេចបណ្តោះអាសន្នណាមួយក្នុងស្ថានភាពលើកលែងបានឡើយលុះត្រាតែ៖

ក- ជាសារធាតុគីមីដែលត្រូវបានចុះបញ្ជីក្នុងប្រទេសភាគីនាំចូល នៅពេលនាំចូល។

ខ- ជាសារធាតុគីមីដែលមានភស្តុតាងបញ្ជាក់ថាធ្លាប់បានប្រើប្រាស់ ឬបាននាំចូលក្នុងប្រទេសភាគីនាំចូល និងសារធាតុគីមីនោះមិនមានវិធានការច្បាប់ដើម្បីហាមឃាត់ការប្រើប្រាស់របស់វាឡើយ។

គ- មានការយល់ព្រមដោយផ្ទាល់លើការនាំចូល ដោយត្រូវបានឃ្លាំមើលនិងទទួលបានដោយអ្នកនាំចេញតាមរយៈអាជ្ញាធរជាតិនៃភាគីនាំចូល។ ភាគី

នាំចូលត្រូវឆ្លើយតបចំពោះសំណើនេះក្នុងរយៈពេល៦០ថ្ងៃ និងត្រូវជូនដំណឹងទៅលេខាធិការដ្ឋានភ្លាមៗនៃការសម្រេចរបស់ខ្លួន។

កាតព្វកិច្ចភាគីនាំចូលក្រោមកថាខណ្ឌនេះត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃផុតកំណត់រយៈពេល៦ខែនៃកាលបរិច្ឆេទដែលលេខាធិការដ្ឋានជូនព័ត៌មានទៅភាគីទាំងអស់ជាលើកដំបូងស្របតាមកថាខណ្ឌទី១០នៃមាត្រា១០ ដែលភាគីមួយខកខានក្នុងការបញ្ជូនការឆ្លើយតបឬបានបញ្ជូនការឆ្លើយតបបណ្តោះអាសន្នដែលមិនមានការសម្រេចណាមួយ និងត្រូវអនុវត្តសម្រាប់រយៈពេលមួយឆ្នាំ។

## មាត្រា ១២.- សេចក្តីជូនដំណឹងពីការនាំចេញ

១- នៅពេលដែលភាគីមួយត្រូវបាននាំចេញពីដែនដីរបស់ខ្លួននូវសារធាតុគីមីហាមឃាត់ឬស្ថិតក្រោមលក្ខខណ្ឌខ្ពស់ ភាគីនោះត្រូវផ្តល់សេចក្តីជូនដំណឹងពីការនាំចេញរបស់ខ្លួនទៅភាគីនាំចូល។ សេចក្តីជូនដំណឹងពីការនាំចេញ ត្រូវរួមបញ្ចូលនូវព័ត៌មានដែលកំណត់ក្នុងឧបសម្ពន្ធទីV។

២- សេចក្តីជូនដំណឹងពីការនាំចេញ ត្រូវបានផ្តល់សម្រាប់សារធាតុគីមីនោះនៅមុនការនាំចេញដំបូងបន្ទាប់ពីការអនុម័តនៃវិធានការច្បាប់ចុងក្រោយ។ បន្ទាប់មកសេចក្តីជូនដំណឹងពីការនាំចេញ ត្រូវផ្តល់នៅមុនពេលនាំចេញដំបូងនៃប្រតិទិនប្រចាំឆ្នាំ។ តម្រូវការនៃការជូនដំណឹងមុនពេលនាំចេញអាចត្រូវបានលើកលែងដោយអាជ្ញាធរជាតិនៃភាគីនាំចូល។

៣- ភាគីនាំចេញត្រូវផ្តល់សេចក្តីជូនដំណឹងថ្មីៗនៃការនាំចេញបន្ទាប់ពីបានអនុម័តវិធានការច្បាប់ចុងក្រោយ ដែលលទ្ធផលផ្លាស់ប្តូរភាគច្រើនពាក់ព័ន្ធនឹងការហាមឃាត់ឬការដាក់លក្ខខណ្ឌនៃសារធាតុគីមីនោះ។

៤- ភាគីនាំចូលត្រូវទទួលស្គាល់ការទទួលយកសេចក្តីជូនដំណឹងនៃការនាំចេញដំបូងបន្ទាប់ពីការអនុម័តវិធានការច្បាប់ចុងក្រោយ។ ប្រសិនបើភាគីនាំចេញមិនបានទទួលចម្លើយតបក្នុងកំឡុងពេល៣០ថ្ងៃនៃការបញ្ជូនដំណឹងពីការនាំចេញ ភាគីនោះត្រូវស្នើបញ្ជូនសេចក្តីជូនដំណឹងជាលើកទី២។ ភាគីប្រទេសនាំចេញត្រូវប្រឹងប្រែងដើម្បីឱ្យប្រាកដថាភាគីនាំចូលបានទទួលសេចក្តីជូនដំណឹងជាលើកទី២ហើយ។

៥- កាតព្វកិច្ចរបស់ភាគីដែលចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវបញ្ឈប់នៅពេលៈ

ក- សារធាតុគីមីត្រូវបានចុះបញ្ជីក្នុងឧបសម្ពន្ធទីIII។

ខ- ភាគីនាំចូលបានផ្តល់ការឆ្លើយតបចំពោះសារធាតុគីមីទៅលេខាធិការដ្ឋានស្របតាមកថាខណ្ឌទី២នៃមាត្រា១០។

គ- លេខាធិការដ្ឋានបានចែកចាយការឆ្លើយតបទៅបណ្តាភាគីស្របនឹងកថាខណ្ឌទី១០នៃមាត្រា១០។

**មាត្រា ១៣.- ព័ត៌មានភ្ជាប់សម្រាប់សារធាតុគីមីនាំចេញ**

១- សន្និបាតភាគីត្រូវជំរុញអង្គការគយពិភពលោកបង្កើតប្រព័ន្ធសុខដុមនីយកម្មលេខកូដទំនិញគយក្នុងការកំណត់លេខកូដជាក់លាក់(Specific Harmonized System Customs code) ទៅលើសារធាតុគីមីនីមួយៗឬក្រុមសារធាតុគីមីដែលមានក្នុងឧបសម្ព័ន្ធទីIII។ នៅពេលលេខកូដត្រូវបានគេកំណត់ចំពោះសារធាតុគីមីទាំងនោះ ភាគីនីមួយៗត្រូវបំពេញតម្រូវការសម្រាប់ឯកសារនាំចេញចំពោះសារធាតុគីមីនោះ ដោយត្រូវភ្ជាប់លេខកូដនៅពេលនាំចេញ។

២- ដោយគ្មានព្យសនកម្មដល់សេចក្តីទាមទាររបស់ភាគីនាំចូលណាមួយ ភាគីនីមួយៗត្រូវទាមទារចំពោះសារធាតុគីមីដែលមានក្នុងឧបសម្ព័ន្ធទីIII សារធាតុគីមីហាមឃាត់ និងសារធាតុគីមីក្រោមលក្ខខណ្ឌខ្ពស់ដែលស្ថិតក្នុងទឹកដីរបស់ខ្លួន គឺនៅពេលដែលនាំចេញជាកម្មវត្ថុនៃការដាក់ស្លាកសញ្ញាដោយធានាថាមានព័ត៌មានគ្រប់គ្រាន់ទាក់ទិននឹងហានិភ័យ និង/ឬគ្រោះថ្នាក់ទាំងឡាយដល់សុខភាពមនុស្សនិងបរិស្ថាន ដោយរាប់បញ្ចូលនូវស្តង់ដាអន្តរជាតិ។

៣- ដោយគ្មានព្យសនកម្មដល់សេចក្តីទាមទាររបស់ភាគីនាំចូលណាមួយ ភាគីនីមួយៗអាចទាមទារចំពោះសារធាតុគីមីដែលជាកម្មវត្ថុនៃការតម្រូវដាក់ស្លាកសញ្ញាសុខភាព និងបរិស្ថានក្នុងទឹកដីរបស់ខ្លួនគឺនៅពេលនាំចេញ ត្រូវទាមទារការដាក់ស្លាកសញ្ញាដែលធានាថាមានព័ត៌មានគ្រប់គ្រាន់ដែលទាក់ទិននឹងហានិភ័យសុខភាពមនុស្ស និងបរិស្ថានដោយរាប់បញ្ចូលនូវស្តង់ដាអន្តរជាតិ។

៤- ចំពោះសារធាតុគីមីដែលកំណត់ក្នុងកថាខណ្ឌទី២នៃមាត្រានេះដែល ត្រូវបានប្រើប្រាស់សម្រាប់គោលបំណងវិជ្ជាជីវៈ ភាគីនាំចេញនីមួយៗអាចតម្រូវឱ្យមានបណ្ណព័ត៌មានសុវត្ថិភាពតាមទម្រង់ដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិបង្ហាញព័ត៌មានដែលមានថ្មីៗបំផុត គឺត្រូវបានបញ្ជូនទៅអ្នកនាំចូលនីមួយៗ។

៥- ព័ត៌មាននៅលើស្លាកសញ្ញា និងនៅលើព្រឹត្តិបត្រព័ត៌មានសុវត្ថិភាពដែលអាចអនុវត្តបានគួរត្រូវបានផ្តល់ក្នុងភាសាមួយឬច្រើននៃភាគីនាំចូល។

**មាត្រា ១៤.- ការផ្លាស់ប្តូរព័ត៌មាន**

១- ដោយអនុលោមតាមគោលបំណងនៃអនុសញ្ញានេះ ភាគីនីមួយៗត្រូវសម្របសម្រួលៈ

ក-ការផ្លាស់ប្តូរព័ត៌មានវិទ្យាសាស្ត្រ សេដ្ឋកិច្ច បច្ចេកទេស និងច្បាប់ដែលទាក់ទងនឹងសារធាតុគីមីក្នុងវិសាលភាពនៃអនុសញ្ញានេះរួមបញ្ចូលនូវព័ត៌មានភាពពុលវិទ្យា

(Toxicology) ព័ត៌មានភាពពុលវិទ្យាបរិស្ថាន(Environmental Toxicology) និងព័ត៌មានសុវត្ថិភាព។

ខ-ការផ្តល់ព័ត៌មានដែលអាចរកបានជាសាធារណៈលើសកម្មភាពផ្លូវច្បាប់ (regulatory actions) ក្នុងស្រុកទាក់ទងទៅនឹងកម្មវត្ថុរបស់អនុសញ្ញានេះ។

គ-ការផ្តល់ព័ត៌មានទៅភាគីផ្សេងៗទៀតដោយផ្ទាល់ឬតាមរយៈលេខាធិការដ្ឋានស្តីពីវិធានការផ្លូវច្បាប់ក្នុងស្រុក ដែលកំណត់លក្ខខណ្ឌមួយឬច្រើនក្នុងការប្រើប្រាស់សារធាតុគីមីតាមជាក់ស្តែង។

២- ភាគីដែលផ្លាស់ប្តូរព័ត៌មានដោយអនុលោមតាមអនុសញ្ញានេះ ត្រូវការពារព័ត៌មានយ៉ាងសម្ងាត់ដូចដែលបានព្រមព្រៀងគ្នាទៅវិញទៅមក។

៣- ព័ត៌មានខាងក្រោមនេះនឹងមិនត្រូវបានចាត់ទុកជាការសម្ងាត់សម្រាប់គោលបំណងនៃអនុសញ្ញានេះឡើយ៖

ក- ព័ត៌មានបានបង្ហាញក្នុងឧបសម្ពន្ធទីI និងទីV ដែលត្រូវបានបញ្ជូនមក ស្របតាមមាត្រា៥ និង៦។

ខ- ព័ត៌មាននៅក្នុងព្រឹត្តិបត្រព័ត៌មានសុវត្ថិភាពដែលយោងតាមកថាខណ្ឌទី៤ នៃមាត្រា១៣។

គ- សារធាតុគីមីហួសកាលកំណត់ការប្រើប្រាស់។

ឃ-ព័ត៌មានស្តីពីវិធានការប្រុងប្រយ័ត្នដែលរួមបញ្ចូលនូវចំណាត់ថ្នាក់គ្រោះថ្នាក់ប្រភេទនៃហានិភ័យ និងការណែនាំពីសុវត្ថិភាពដែលទាក់ទង។

ង- លទ្ធផលសង្ខេបនៃការសាកល្បងភាពពុល និងភាពពុលវិទ្យាបរិស្ថាន។

៤- កាលបរិច្ឆេទនៃផលិតកម្មសារធាតុគីមី ជាទូទៅមិនត្រូវបានចាត់ទុកជាការសម្ងាត់ទេសម្រាប់គោលបំណងអនុសញ្ញានេះ។

៥- ភាគីណាមួយដែលត្រូវការព័ត៌មានស្តីពីចលនាឆ្លងកាត់(transit movements) តាមរយៈដែនដីរបស់ខ្លួននៃសារធាតុគីមីមានក្នុងឧបសម្ពន្ធទីIII អាចរាយការណ៍ពីសេចក្តីត្រូវការរបស់ខ្លួនដល់លេខាធិការដ្ឋានដែលត្រូវជូនព័ត៌មានទៅគ្រប់ភាគីទាំងអស់តាមការចាំបាច់។

**មាត្រា ១៥.- ការអនុវត្តអនុសញ្ញា**

១- ភាគីនីមួយៗត្រូវចាត់វិធានការនៅពេលចាំបាច់ ដើម្បីបង្កើត និងពង្រឹងស្ថាប័ននិងហេដ្ឋារចនាសម្ពន្ធជាតិរបស់ខ្លួន សម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធភាពចំពោះអនុសញ្ញានេះ។ វិធានការនេះអាចរួមបញ្ចូលតាមតម្រូវការនូវការអនុម័តឬវិសោធនកម្មវិធានការច្បាប់ឬរដ្ឋបាលជាតិ ហើយអាចរួមបញ្ចូលផងដែរនូវ៖

ក-ការបង្កើតស្ថាប័នចុះបញ្ជីនិងមូលដ្ឋានទិន្នន័យថ្នាក់ជាតិ ដោយរួមបញ្ចូលនូវព័ត៌មានសុវត្ថិភាពសម្រាប់សារធាតុគីមី។

ខ-ជំរុញការផ្តួចផ្តើមដោយពោងចក្រឧស្សាហកម្ម ដើម្បីលើកកម្ពស់សុវត្ថិភាពចំពោះសារធាតុគីមី។

គ-លើកស្ទួយរាល់កិច្ចព្រមព្រៀងស្ម័គ្រចិត្តដែលពិចារណាលើបទប្បញ្ញត្តិនៃមាត្រា១៦។

២- ភាគីនីមួយៗត្រូវជានាចំពោះការពង្រីកការអនុវត្តជាក់ស្តែងធ្វើឱ្យមជ្ឈដ្ឋានសាធារណៈមានលទ្ធភាពទទួលបាននូវព័ត៌មានស្តីពីការប្រើប្រាស់និងការគ្រប់គ្រងពីគ្រោះថ្នាក់របស់សារធាតុគីមី និងស្តីពីការផ្លាស់ប្តូរជំនួសសារធាតុគីមីដែលមានសុវត្ថិភាពសម្រាប់សុខភាពមនុស្សឬបរិស្ថានជាងសារធាតុគីមីដែលមានក្នុងឧបសម្ពន្ធទីIII។

៣- ភាគីទាំងអស់យល់ព្រមសហការដោយផ្ទាល់ឬនៅកន្លែងជាក់ស្តែងតាមរយៈអង្គការអន្តរជាតិដែលមានសមត្ថកិច្ចក្នុងការអនុវត្តអនុសញ្ញានេះនៅកម្រិតអនុតំបន់ តំបន់និងសាកល។

៤- គ្មានអ្វីក្នុងអនុសញ្ញានេះ ត្រូវបានបកស្រាយថាបានកម្រិតសិទ្ធិរបស់ភាគីក្នុងការចាត់វិធានការដែលការពារយ៉ាងតឹងរឹងចំពោះសុខភាពមនុស្ស និង បរិស្ថាន ជាងអ្វីដែលបានអំពាវនាវក្នុងអនុសញ្ញានេះឱ្យតែវិធានការនោះមានសង្គតិភាពជាមួយនឹងបញ្ញត្តិនៃអនុសញ្ញានេះ និងអនុលោមតាមច្បាប់អន្តរជាតិ។

**មាត្រា ១៦.- ជំនួយការបច្ចេកទេស**

គ្រប់ភាគីទាំងអស់ត្រូវរាប់បញ្ចូលដោយឡែកនូវតម្រូវការសហប្រតិបត្តិការរបស់ប្រទេសកំពុងអភិវឌ្ឍ និងប្រទេសដែលមានសេដ្ឋកិច្ចស្ថិតក្នុងអន្តរកាលក្នុងជំនួយបច្ចេកទេសសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងសមត្ថភាពចាំបាច់ក្នុងការគ្រប់គ្រងសារធាតុគីមីដើម្បីអាចអនុវត្តអនុសញ្ញាបាន។ បណ្តាភាគីដែលមានកម្មវិធី ឈានមុខច្រើនសម្រាប់ធ្វើនិយ័តកម្មសារធាតុគីមីត្រូវផ្តល់ជំនួយការខាងបច្ចេកទេស រួមមានការបណ្តុះបណ្តាលទៅភាគីដទៃទៀតក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងសមត្ថភាពរបស់ពួកគេដើម្បីគ្រប់គ្រងសារធាតុគីមីក្នុងវដ្តជីវិតរបស់វា។

**មាត្រា ១៧.- ភាពមិនអនុលោម**

សន្និបាតនៃភាគីត្រូវបង្កើតនិងអនុម័តឱ្យបានឆាប់បំផុតលើនីតិវិធីនិងបណ្តាយន្តការរបស់ស្ថាប័ន សម្រាប់កំណត់ភាពមិនអនុលោមជាមួយនឹងបទប្បញ្ញត្តិដែលចែងនៅក្នុងអនុសញ្ញានេះ និងសម្រាប់អនុវត្តចំពោះភាគីណាដែលរកឃើញថាស្ថិតក្នុងភាពមិនអនុលោម។

**មាត្រា ១៨.- សន្និបាតភាគី**

១- សន្និបាតភាគីត្រូវបានការបង្កើតឡើងដូចតទៅនេះ។

២- កិច្ចប្រជុំលើកទី១នៃសន្និបាតភាគីនឹងត្រូវបានកោះប្រជុំរួមគ្នាដោយនាយកប្រតិបត្តិរបស់កម្មវិធីបរិស្ថានសហប្រជាជាតិ(UNEP) និងអគ្គលេខាធិការអង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ(FAO)មិនឱ្យលើសពី១ឆ្នាំ បន្ទាប់ពីអនុសញ្ញានេះត្រូវបានចូលជាធរមាន។ បន្ទាប់មកការប្រជុំសាមញ្ញរបស់សន្និបាតភាគីត្រូវរៀបចំឡើងក្នុងចន្លោះពេលដ៏ទៀងទាត់ដែលនឹងត្រូវកំណត់ដោយសន្និបាត។

៣- ការប្រជុំវិសាមញ្ញសន្និបាតភាគីត្រូវធ្វើឡើងនៅពេលវេលាផ្សេងតាមការចាំបាច់ដោយយោងតាមសន្និបាតឬតាមសំណូមពរជាលាយលក្ខណ៍អក្សរដោយភាគីណាមួយល្គឹកណាមានសម្លេងគាំទ្រ១/៣(មួយភាគបី)នៃភាគីទាំងអស់។

៤- នៅក្នុងកិច្ចប្រជុំលើកទី១ សន្និបាតភាគីត្រូវយល់ព្រមដោយឯកច្ឆ័ន្ទនិងត្រូវអនុម័តនូវបទបញ្ជានៃសន្និបាត និងបទបញ្ជាគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់សន្និបាតនិងគណៈកម្មការចំណុះ ក៏ដូចជាការផ្តល់ថវិកាសម្រាប់ការបំពេញភារកិច្ចរបស់លេខាធិការដ្ឋានដែរ។

៥- សន្និបាតរបស់ភាគីជានិច្ចជាកាលត្រូវរក្សាការត្រួតពិនិត្យបន្តបន្ទាប់ និងវាយតម្លៃការប្រតិបត្តិអនុសញ្ញានេះ។ សន្និបាតរបស់ភាគីត្រូវបំពេញភារកិច្ចរបស់ខ្លួនដែលកំណត់ដោយអនុសញ្ញារហូតដល់ទីបញ្ចប់ហើយត្រូវៈ

ក- យោងទៅលើតម្រូវការនៅកថាខណ្ឌទី៦ខាងក្រោម ចាំបាច់ត្រូវបង្កើតគណៈកម្មការចំណុះសម្រាប់ការប្រតិបត្តិអនុសញ្ញានេះ។

ខ- សហការតាមភាពជាក់ស្តែងជាមួយអង្គការមានសមត្ថកិច្ចអន្តរជាតិ អង្គការអន្តររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល។

គ- ពិចារណានិងទទួលរ៉ាប់រងនូវសកម្មភាពបន្ថែម ដែលអាចតម្រូវឡើងដើម្បីឈានទៅសម្រេចបាននូវកម្មវត្ថុនៃអនុសញ្ញានេះ។

៦- នៅក្នុងកិច្ចប្រជុំលើកទី១ សន្និបាតភាគីត្រូវបង្កើតគណៈកម្មការចំណុះមួយដែលមានឈ្មោះថាគណៈកម្មការត្រួតពិនិត្យសារធាតុគីមី(Chemical Review Committee) ក្នុងគោលបំណងបំពេញមុខងារដែលកំណត់ដោយអនុសញ្ញា រួមមានៈ

ក- សមាជិករបស់គណៈកម្មការត្រួតពិនិត្យសារធាតុគីមី ត្រូវបានចាត់តាំងដោយសន្និបាតភាគី។ សមាជិកភាពរបស់គណៈកម្មការត្រូវមានចំនួនកំណត់ និងជាអ្នកឯកទេសដែលមានជំនាញក្នុងផ្នែកវាយតម្លៃនិងគ្រប់គ្រងសារធាតុគីមីដែលបានចាត់តាំងដោយរដ្ឋាភិបាលនៃភាគី។ សមាជិករបស់គណៈកម្មការត្រូវបានតែងតាំងឈរលើមូលដ្ឋានបែងចែកតាមភូមិសាស្ត្រស្មើភាព រួមមានការធានាតុល្យភាពរវាងភាគីនៃប្រទេសកំពុងអភិវឌ្ឍនិងប្រទេសអភិវឌ្ឍ។

ខ- សន្និបាតភាគីត្រូវធ្វើការសម្រេចពីលក្ខខណ្ឌការងារ ការចាត់តាំង និង ប្រតិបត្តិការរបស់គណៈកម្មការខាងលើ។

គ- គណៈកម្មការត្រូវខិតខំដើម្បីអនុម័តនូវអនុសាសន៍របស់ខ្លួនដោយឯកច្ឆ័ន្ទ។ ប្រសិនបើការប្រឹងប្រែងចំពោះឯកច្ឆ័ន្ទភាពនោះត្រូវបានពិភាក្សាយ៉ាងល្អិតល្អន់ តែមិនទទួលបានការឯកភាពជាឯកច្ឆ័ន្ទ មធ្យោបាយក្រោយបំផុតគឺអនុសាសន៍ ទាំងនោះ នឹងត្រូវដាក់ឱ្យអនុម័តដោយសម្លេងឆ្នោត២/៣(ពីរភាគបី)នៃ ចំនួនសមាជិកវត្តមាន។

៧- អង្គការសហប្រជាជាតិ ភ្នាក់ងារជំនាញរបស់អង្គការនេះ និងភ្នាក់ងារថាមពល អាតូមិកអន្តរជាតិ ក៏ដូចជារដ្ឋដែលមិនមែនជាភាគីរបស់អនុសញ្ញានេះ អាចចូល រួមជាអ្នកសង្កេតការណ៍នៅក្នុងការប្រជុំសន្និបាតភាគី។ អង្គការឬភ្នាក់ងារណាមួយ ទោះថ្នាក់ជាតិ អន្តរជាតិ រដ្ឋាភិបាល ឬក្រៅរដ្ឋាភិបាល ដែលមានលក្ខណសម្បត្តិ សមស្របទៅនឹងអនុសញ្ញា និងដែលបានជម្រាបទៅលេខាធិការដ្ឋាននូវគោល បំណងខ្លួនដើម្បីមានវត្តមាននៅក្នុងកិច្ចប្រជុំសន្និបាតភាគីក្នុងនាមជាអ្នកសង្កេត ការណ៍ អាចត្រូវបានអនុញ្ញាតលុះត្រាតែយ៉ាងតិចបំផុតចំនួន១/៣(មួយភាគ បី) នៃភាគីវត្តមានមិនធ្វើការជំទាស់។ ការអនុញ្ញាតឱ្យចូលនិងការចូលរួមរបស់អ្នក សង្កេតការណ៍ត្រូវគោរពតាមបទបញ្ជានិងនីតិវិធីដែលបានអនុម័តដោយសន្និបាត ភាគី។

## មាត្រា ១៩.- លេខាធិការដ្ឋាន

១- លេខាធិការដ្ឋានមួយត្រូវបានបង្កើតឡើងតាមរយៈអនុសញ្ញានេះ។

២- តួនាទីភារកិច្ចរបស់លេខាធិការដ្ឋានត្រូវ៖

ក- ធ្វើការរៀបចំការប្រជុំសន្និបាតភាគីនិងគណៈកម្មាធិការអនុសញ្ញា និងផ្តល់ សេវាដល់ការងារទាំងនោះតាមការស្នើសុំ។

ខ- ធ្វើការសម្របសម្រួលជួយដល់ភាគីទាំងអស់ ជាពិសេសភាគីដែលជាប្រទេស កំពុងអភិវឌ្ឍ និងភាគីជាប្រទេសដែលមានសេដ្ឋកិច្ចអន្តរភាពតាមសំណូមពរ ក្នុងការអនុវត្តអនុសញ្ញានេះ។

គ- ធានាការសម្របសម្រួលចាំបាច់ជាមួយនឹងលេខាធិការដ្ឋាននៃអង្គការអន្តរជាតិ ពាក់ព័ន្ធដទៃទៀត។

ឃ-ចូលរួមក្នុងកិច្ចការរដ្ឋបាល និងការរៀបចំកិច្ចសន្យាដែលនឹងអាចស្នើសម្រាប់ ប្រសិទ្ធភាពនៃការបំពេញភារកិច្ចរបស់នៅក្រោមការណែនាំទូទៅនៃសន្និបាត ភាគី។

ង- បំពេញតួនាទីផ្សេងទៀតរបស់លេខាធិការដ្ឋាន ដែលបានបញ្ជាក់ក្នុងអនុសញ្ញា និងមុខនាទីដទៃទៀតដែលត្រូវបានកំណត់ដោយសន្និបាតភាគី។

៣- មុខនាទីរបស់លេខាធិការដ្ឋាននៃអនុសញ្ញានេះនឹងត្រូវបានរៀបចំរួមគ្នាដោយនាយកប្រតិបត្តិនៃកម្មវិធីបរិស្ថានសហប្រជាជាតិ(UNEP) និងអគ្គនាយកអង្គការស្បៀង និងកសិកម្មសហប្រជាជាតិ(FAO) ដោយត្រូវមានការយល់ព្រមរវាងគ្នា និងបានអនុម័តដោយសន្និបាតភាគី។

៤- សន្និបាតភាគីអាចសម្រេចដោយសម្លេងភាគច្រើន៣/៤(បីភាគបួន) នៃភាគីមានវត្តមានពេលបោះឆ្នោតដើម្បីធ្វើឱ្យមានការជឿជាក់លើមុខនាទីរបស់លេខាធិការដ្ឋានចំពោះអង្គការអន្តរជាតិមានសមត្ថកិច្ចមួយឬច្រើន ដែលគួររកឃើញថាលេខាធិការដ្ឋានមិនបានបំពេញមុខងារតាមចំណង់បានឡើយ។

**មាត្រា ២០.- ដំណោះស្រាយជម្លោះ**

១- ភាគីទាំងអស់ត្រូវដោះស្រាយនូវជម្លោះរវាងគ្នាដែលទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញានេះ តាមរយៈការចរចាឬមធ្យោបាយសន្តិវិធីផ្សេងទៀតតាមជម្រើសរបស់ពួកគេ។

២- នៅពេលដែលធ្វើសច្ចានុម័ត ការទទួលយកការអនុម័ត ឬការសុំចូលអនុសញ្ញានេះ ឬនៅពេលណាមួយក្រោយមកក្តីភាគីមួយដែលមិនមែនជាអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់អាចធ្វើប្រកាសនៅក្នុងលិខិតុបករណ៍លាយលក្ខណ៍អក្សរដាក់ជូនកន្លែងតម្កល់ឯកសារដោយគោរពចំពោះជម្លោះណាមួយពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញានេះ គេទទួលស្គាល់នូវវិធីមួយឬទាំងពីរនៃដំណោះស្រាយជម្លោះខាងក្រោមជាចាំបាច់ក្នុងការទាក់ទងជាមួយនឹងភាគីណាមួយដែលបានទទួលយកកាតព្វកិច្ចដូចគ្នា៖

ក- មជ្ឈត្តកម្ម ដោយអនុលោមទៅតាមនីតិវិធីដែលនឹងត្រូវបានអនុម័តដោយសន្និបាតភាគីក្នុងឧបសម្ពន្ធមួយកាន់តែឆាប់តាមដែលនឹងត្រូវបង្កើតនៅពេលឆាប់ៗខាងមុខ។

ខ- ការដាក់រឿងក្តីជម្លោះទៅតុលាការអន្តរជាតិដោះស្រាយ។

៣- ភាគីមួយដែលជាអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ អាចធ្វើសេចក្តីប្រកាសដោយមានប្រសិទ្ធភាពក្នុងទំនាក់ទំនងទៅនឹងមជ្ឈត្តករ ដោយអនុលោមទៅនឹងនីតិវិធីយោងតាមកថាខណ្ឌទី២(ក)។

៤- សេចក្តីប្រកាសដែលបានធ្វើឡើងតាមកថាខណ្ឌទី២ ត្រូវរក្សាជាធរមានរហូតដល់ហួសពេលផុតកំណត់របស់វា ដោយអនុលោមទៅតាមសុពលភាពរបស់វា ឬរហូត

ដល់៣ខែក្រោយពេលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរនៃការដកហូតវិញ ត្រូវបានដាក់ទៅការិយាល័យតម្កល់ឯកសារ។

៥- ការផុតកំណត់នៃសេចក្តីប្រកាស សេចក្តីជូនដំណឹងនៃការដកហូតមកវិញ ឬ សេចក្តីប្រកាសថ្មីមួយនឹងមិនត្រូវបានប៉ះពាល់លើទម្រង់ការនៃការព្យួរទុកមុនសាលាក្តីមជ្ឈត្តកម្មឬតុលាការអន្តរជាតិវិនិច្ឆ័យ លុះត្រាណាតែភាគីជម្លោះទាំងពីរយល់ព្រមផ្សេង។

៦- ប្រសិនបើភាគីជម្លោះមិនបានយល់ព្រមដូចគ្នា ឬស្របតាមនីតិវិធីណាមួយតាមកថាខណ្ឌទី២នៃមាត្រានេះ និងប្រសិនបើគេពុំមានលទ្ធភាពដោះស្រាយជម្លោះរបស់គេក្នុងរយៈពេល១២ខែ បន្ទាប់ពីសេចក្តីជូនដំណឹងដោយភាគីមួយទៅភាគីផ្សេងទៀតហើយជម្លោះនេះនៅតែកើតមានរវាងពួកគេ ជម្លោះនោះត្រូវដាក់ជូនគណៈកម្មការផ្សះផ្សាតាមសំណូមពររបស់ភាគីជម្លោះណាមួយ។ គណៈកម្មការផ្សះផ្សាជម្លោះត្រូវផ្តល់របាយការណ៍មួយភ្ជាប់ជាមួយអនុសាសន៍។ នីតិវិធីបន្ថែមទៀតដែលទាក់ទងទៅនឹងគណៈកម្មការផ្សះផ្សាជម្លោះ ត្រូវរួមបញ្ចូលទៅក្នុងឧបសម្ព័ន្ធមួយដែលនឹងត្រូវអនុម័តដោយសន្និបាតភាគីមិនឱ្យយឺតជាងពេលប្រជុំសន្និបាតលើកទី២ឡើយ។

**មាត្រា ២១.- ការធ្វើវិសោធនកម្មអនុសញ្ញា**

១- ការធ្វើវិសោធនកម្មលើអនុសញ្ញានេះអាចនឹងត្រូវធ្វើបានតាមរយៈការស្នើសុំដោយភាគីណាមួយ។

២- ការធ្វើវិសោធនកម្មនេះនឹងត្រូវបានអនុម័តក្នុងកិច្ចប្រជុំសន្និបាតភាគី។ អត្ថបទស្តីពីការធ្វើវិសោធនកម្មដែលបានស្នើសុំនឹងត្រូវបញ្ជូនទៅភាគីទាំងអស់ដោយលេខាធិការដ្ឋានយ៉ាងហោចណាស់០៦(ប្រាំមួយ)ខែនៅមុនពេលប្រជុំដើម្បីស្នើសុំការអនុម័ត។ លេខាធិការដ្ឋានត្រូវបញ្ជូនការស្នើសុំធ្វើវិសោធនកម្មនេះទៅប្រទេសជាហត្ថលេខីនៃអនុសញ្ញានេះ និងទៅការិយាល័យតម្កល់ឯកសារសម្រាប់ជាព័ត៌មាន។

៣- ភាគីទាំងអស់ត្រូវខិតខំដើម្បីឈានដល់ការព្រមព្រៀងលើការស្នើសុំធ្វើវិសោធនកម្មអនុសញ្ញានេះដោយការយល់ព្រមជាឯកច្ឆ័ន្ទ។ ប្រសិនបើការខិតខំទាំងអស់ធ្វើឡើងដោយមានការពិភាក្សាយ៉ាងល្អិតល្អន់ហើយ នៅតែពុំអាចឈានដល់ការព្រមព្រៀងទៀត ការធ្វើវិសោធនកម្មនឹងត្រូវដោះស្រាយតាមមធ្យោបាយចុងក្រោយដែលនឹងត្រូវអនុម័តដោយការបោះឆ្នោតតាមរយៈសម្លេងភាគច្រើន៣/៤(បីភាគបួន)នៃភាគីដែលវត្តមាននៅក្នុងកិច្ចប្រជុំសន្និបាតភាគី ។

៤- បញ្ញត្តិវិសោធនកម្មដែលបានធ្វើរួច ត្រូវបញ្ជូនដោយការិយាល័យតម្កល់ឯកសារទៅកាន់គ្រប់ភាគីទាំងអស់ដើម្បីផ្តល់សច្ចានុម័ត ទទួលយក ឬអនុម័តយល់ព្រម ។

៥- ការផ្តល់សច្ចានុម័ត ការទទួលយក ឬការយល់ព្រមលើការធ្វើវិសោធនកម្ម ត្រូវបានជូនដំណឹងទៅការិយាល័យតម្កល់ឯកសារជាលាយលក្ខណ៍អក្សរ។ វិសោធនកម្មដែលបានអនុម័តអនុលោមតាមវាក្យខណ្ឌទី៣ នៃមាត្រានេះនឹងត្រូវចូលជាធរមានសម្រាប់ភាគីដែលបានយល់ព្រមក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ ក្រោយថ្ងៃដែលបានតម្កល់ឯកសារនៃការធ្វើសច្ចានុម័ត ការទទួលយក ឬការយល់ព្រម យ៉ាងហោចណាស់ដោយសម្លេង៣/៤(បីភាគបួន)នៃភាគី។ បន្ទាប់មកការធ្វើវិសោធនកម្មនឹងត្រូវដាក់ជាធរមានសម្រាប់ភាគីណាមួយផ្សេងទៀតក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ ក្រោយថ្ងៃដែលភាគីនោះតម្កល់នូវលិខិតុបករណ៍នៃការធ្វើសច្ចានុម័ត ទទួលយក ឬយល់ព្រមលើការធ្វើវិសោធនកម្ម។

**មាត្រា ២២.- ការអនុម័តនិងការធ្វើវិសោធនកម្មឧបសម្ព័ន្ធ**

១- ឧបសម្ព័ន្ធរបស់អនុសញ្ញានេះនឹងបង្កើតជាផ្នែករួមទាំងមូល និងជាឯកសារយោងចំពោះផ្នែកពាក់ព័ន្ធដទៃទៀតរបស់អនុសញ្ញានេះ ហើយទន្ទឹមនេះក៏ជាសេចក្តីយោងចំពោះឧបសម្ព័ន្ធដទៃទៀតដែលមានស្រាប់។

២- ឧបសម្ព័ន្ធនឹងត្រូវបានកំណត់លក្ខខណ្ឌទៅនឹងបញ្ហានៃនីតិវិធី វិទ្យាសាស្ត្រ បច្ចេកទេស ឬរដ្ឋបាល។

៣- នីតិវិធីខាងក្រោមនឹងអនុវត្តចំពោះការស្នើការអនុម័ត និងការចូលជាធរមាននៃឧបសម្ព័ន្ធបន្ថែមចំពោះអនុសញ្ញានេះ៖

ក- ឧបសម្ព័ន្ធបន្ថែមនឹងត្រូវបានស្នើ និងបានអនុម័តដោយយោងទៅតាមនីតិវិធីដែលបានចែងក្នុងវាក្យខណ្ឌទី១ វាក្យខណ្ឌទី២ និងវាក្យខណ្ឌទី៣ នៃមាត្រា២១។

ខ- ភាគីណាមួយមិនមានលទ្ធភាពដើម្បីយល់ព្រមតាមឧបសម្ព័ន្ធបន្ថែម ត្រូវជូនដំណឹងទៅការិយាល័យតម្កល់ឯកសារជាលាយលក្ខណ៍អក្សរក្នុងរយៈពេល១ឆ្នាំគិតចាប់ពីថ្ងៃដែលបានទទួលឯកសារពីការអនុម័តនៃឧបសម្ព័ន្ធបន្ថែម។ ការិយាល័យតម្កល់ឯកសារដោយមិនពន្យាពេល ត្រូវជូនដំណឹងទៅរាល់ភាគីដែលខ្លួនបានទទួលនូវសេចក្តីជូនដំណឹង។ ភាគីមួយអាចដកវិញគ្រប់ពេលនូវសេចក្តីជូនដំណឹងលើកមុននៃការមិនយល់ព្រមក្នុងការគោរពចំពោះ

ឧបសម្ព័ន្ធបន្ថែមនិងឧបសម្ព័ន្ធនោះ ហើយដែលត្រូវបានចូលជាធរមានសម្រាប់ភាគីទាំងអស់អនុលោមតាមអនុកថាខណ្ឌ(គ)។

គ- ក្រោយរយៈពេល០១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃនៃការផ្តល់ព័ត៌មានដោយការិយាល័យតម្កល់ឯកសារស្តីពីការអនុម័តឧបសម្ព័ន្ធបន្ថែមឧបសម្ព័ន្ធនឹងចូលជាធរមានសម្រាប់រាល់ភាគីទាំងអស់ដែលមិនបានដាក់ការជូនដំណឹងជាមុន ដោយអនុលោមទៅតាមបទប្បញ្ញត្តិដែលចែងក្នុងកថាខណ្ឌ(ខ) ខាងលើ ។

៤- លើកលែងចំពោះឧបសម្ព័ន្ធទីIII សំណើសុំការអនុម័តនិងការចូលជាធរមាននូវការធ្វើវិសោធនកម្មឧបសម្ព័ន្ធនៃអនុសញ្ញានេះត្រូវស្ថិតនៅក្រោមនីតិវិធីដូចគ្នានឹងការស្នើសុំការអនុម័តនិងការចូលជាធរមាននូវឧបសម្ព័ន្ធបន្ថែមដែរ។

៥- នីតិវិធីខាងក្រោមត្រូវអនុវត្តចំពោះការធ្វើសំណើ ការអនុម័ត និងការចូលជាធរមាននូវវិសោធនកម្មឧបសម្ព័ន្ធទីIII៖

ក- ការធ្វើវិសោធនកម្មនឹងត្រូវបានស្នើសុំនិងអនុម័តយោងទៅតាមនីតិវិធីដូចមានចែងក្នុងមាត្រា៥ ដល់៩ និងវាក្យខណ្ឌទី២ នៃមាត្រា២១។

ខ- សន្និបាតភាគីត្រូវធ្វើការសម្រេចចិត្តលើការអនុម័តរបស់ខ្លួនដោយការឯកភាពជាឯកច្ឆ័ន្ទ។

គ- សេចក្តីសម្រេចចិត្តមួយដើម្បីធ្វើវិសោធនកម្មឧបសម្ព័ន្ធទីIII នឹងត្រូវធ្វើការផ្សព្វផ្សាយឱ្យបានដឹងភ្លាមទៅភាគីទាំងអស់ដោយការិយាល័យតម្កល់ឯកសារ។ សេចក្តីវិសោធនកម្មនឹងត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការសម្រាប់គ្រប់ភាគីទាំងអស់នៅថ្ងៃដូចបានកំណត់ក្នុងសេចក្តីសម្រេច។

៦- ប្រសិនបើឧបសម្ព័ន្ធបន្ថែមឬការធ្វើវិសោធនកម្មចំពោះឧបសម្ព័ន្ធមួយត្រូវបានទាក់ទងនឹងការធ្វើវិសោធនកម្មអនុសញ្ញានេះ ឧបសម្ព័ន្ធបន្ថែមឬការធ្វើវិសោធនកម្មនោះនឹងមិនត្រូវបានចូលជាធរមានទេរហូតដល់ពេលមួយដែលការធ្វើវិសោធនកម្មនៃអនុសញ្ញានេះបានចូលជាធរមាន។

**មាត្រា ២៣.- សិទ្ធិបោះឆ្នោត**

១- ភាគីនីមួយៗរបស់អនុសញ្ញានេះត្រូវមានសិទ្ធិបោះឆ្នោតដោយ១សម្លេង លើកលែងករណីដូចបានចែងក្នុងវាក្យខណ្ឌទី២ខាងក្រោម។

២- ផ្អែកលើសមត្ថកិច្ចរបស់ខ្លួនអង្គការសមាហរណកម្មសេដ្ឋកិច្ចមួយត្រូវប្រើសិទ្ធិរបស់គេដើម្បីបោះឆ្នោត ដោយចំនួនសម្លេងស្មើនឹងចំនួនសមាជិករដ្ឋរបស់ខ្លួនដែលជា

ភាគីនៃអនុសញ្ញានេះ។ អង្គការនេះនឹងមិនត្រូវប្រើសិទ្ធិរបស់គេដើម្បីបោះឆ្នោតទេ ប្រសិនបើរដ្ឋរបស់គេបានប្រើសិទ្ធិរបស់ខ្លួនដើម្បីធ្វើការបោះឆ្នោតនិងផ្ទុយមកវិញ។

៣- គោលបំណងនានានៃអនុសញ្ញានេះ "ភាគីដែលមានវត្តមាននិងបោះឆ្នោត" មានន័យថាជាភាគីវត្តមាននិងសម្តែងនូវសម្លេងឆ្នោតវិជ្ជមានឬអវិជ្ជមាន។

**មាត្រា ២៤.- ការចុះហត្ថលេខា**

អនុសញ្ញានេះនឹងត្រូវបើកចំហរដើម្បីចុះហត្ថលេខានៅទីក្រុងរ៉ូថឺដាម (Rotterdam) សម្រាប់រដ្ឋទាំងអស់និងអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៩៨ នៅទីស្នាក់ការកណ្តាលអង្គការសហប្រជាជាតិនាទីក្រុងញូវយ៉ក ពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៩៨ ដល់ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៩ ។

**មាត្រា ២៥.- ការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការសុំចូល**

១- អនុសញ្ញានេះត្រូវដាក់ឱ្យផ្តល់សច្ចាប័ន ទទួលយក ឬយល់ព្រមដោយរដ្ឋ និងដោយអង្គការសមាហរណកម្មសេដ្ឋកិច្ច។ វានឹងបើកទូលាយសម្រាប់ការសុំចូលដោយរដ្ឋ និងដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ចាប់ពីថ្ងៃដែលអនុសញ្ញានេះបានបិទលែងឱ្យមានការចុះហត្ថលេខា។ លិខិតុបករណ៍សម្រាប់ធ្វើសច្ចានុម័តការទទួលយក ការយល់ព្រម ឬការសុំចូលនឹងត្រូវតម្កល់ទុកនៅការិយាល័យតម្កល់ឯកសារ។

២- អង្គការសមាហរណកម្មសេដ្ឋកិច្ចណាមួយដែលក្លាយទៅជាភាគីរបស់អនុសញ្ញានេះ ដោយពុំមានសមាជិកនៃរដ្ឋណាមួយរបស់ខ្លួនជាភាគីនៃអនុសញ្ញានេះនឹងត្រូវអនុវត្តកាតព្វកិច្ចទាំងអស់របស់អនុសញ្ញានេះ។ ក្នុងករណីដែលសមាជិករដ្ឋមួយឬច្រើននៃអង្គការនេះ ជាភាគីនៃអនុសញ្ញានេះ អង្គការនេះនិងសមាជិករបស់ខ្លួននឹងត្រូវសម្រេចលើការទទួលខុសត្រូវរៀងៗខ្លួន ដើម្បីអនុវត្តភារកិច្ចរបស់គេក្រោមអនុសញ្ញានេះ។ ក្នុងករណីនេះ អង្គការនិងរដ្ឋជាសមាជិករបស់គេនឹងមិនត្រូវបានផ្តល់សិទ្ធិប្រជែងគ្នាក្រោមអនុសញ្ញានេះឡើយ។

៣- ក្នុងលិខិតុបករណ៍សម្រាប់ការផ្តល់សច្ចានុម័ត ការទទួលយក ការយល់ព្រម ការអនុម័ត ឬការសុំចូល អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ត្រូវធ្វើការប្រកាសនូវវិសាលភាពដែនសមត្ថកិច្ចរបស់ខ្លួន ចំពោះអ្វីដែលបានគ្រប់គ្រងដោយអនុសញ្ញានេះ។ អង្គការបែបនេះត្រូវជូនដំណឹងផងដែរទៅការិយាល័យតម្កល់ឯកសារដែលមានភារៈជូនដំណឹងទៅភាគីផ្សេងៗនូវអ្វីដែលទាក់ទងនឹងការកែប្រែនូវវង្វង់ដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា ២៦.- ការចូលជាធរមាន**

១- អនុសញ្ញានេះនឹងចូលជាធរមានក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការដាក់តម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចានុម័ត ការទទួលយក ការយល់ព្រម ឬការសុំចូលចំនួន៥០។

២- សម្រាប់ប្រទេសនីមួយៗឬអង្គការសមាហរណកម្មក្នុងតំបន់ដែលផ្តល់សច្ចានុម័ត ទទួលយក ឬយល់ព្រមលើអនុសញ្ញានេះ ឬក៏សុំចូលជាសមាជិកក្រោយពីការដាក់តម្កល់លិខិតុបករណ៍ទី៥០ នៃការផ្តល់សច្ចានុម័ត ការទទួលយក ការយល់ព្រម ឬការសុំចូលអនុសញ្ញានោះមក អនុសញ្ញានេះនឹងចូលជាធរមានក្នុងរយៈពេល ៩០ថ្ងៃក្រោយកាលបរិច្ឆេទនៃការតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចានុម័ត ការទទួលយក ការយល់ព្រម ឬការសុំចូលនៃរដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចរបស់ខ្លួន។

៣-សម្រាប់គោលបំណងនៅក្នុងវាក្យខណ្ឌទី១និងទី២ លិខិតុបករណ៍ណាមួយដែលបានដាក់តម្កល់ដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់នឹងមិនត្រូវរាប់បញ្ចូលបន្ថែមឡើយចំពោះឯកសារបែបបទដែលត្រូវបានដាក់តម្កល់ដោយប្រទេសជាសមាជិករបស់អង្គការនោះឡើយ។

**មាត្រា ២៧.- ការបម្រុងទុក**

មិនមានការបម្រុងទុកណាមួយដែលត្រូវបានធ្វើឡើងចំពោះអនុសញ្ញានេះទេ។

**មាត្រា ២៨.- ការដកចេញ**

១- នៅគ្រប់ពេលក្រោយរយៈពេល៣(បី)ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុសញ្ញានេះចូលជាធរមានសម្រាប់ភាគីណាមួយ ភាគីនោះអាចដកខ្លួនចេញពីអនុសញ្ញាដោយធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅការិយាល័យតម្កល់ឯកសារ។

២- ការដកចេញនឹងចូលជាធរមាននៅថ្ងៃផុតកំណត់រយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃដែលការិយាល័យតម្កល់ឯកសារទទួលចេញសេចក្តីជូនដំណឹងពីការដកចេញ ឬលើកាលបរិច្ឆេទចុងក្រោយ ដូចបានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងដែលបានដកខ្លួន។

**មាត្រា ២៩.- ការិយាល័យតម្កល់ឯកសារ**

អគ្គលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិគឺជាការិយាល័យតម្កល់ឯកសាររបស់អនុសញ្ញានេះ។

**មាត្រា ៣០.- អត្ថបទយថាភូត**

ឯកសារច្បាប់ដើមផ្លូវការនៃអនុសញ្ញានេះមានជាអក្សរ អារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតម្លៃផ្លូវការដូចគ្នា និងត្រូវតម្កល់ទុកនៅអគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិ។

ដើម្បីជាសក្ខីភាពការចុះហត្ថលេខា ខាងក្រោមត្រូវបានផ្តល់អំណាចចំពោះការចូលជាធរមាន ហើយបានចុះហត្ថលេខាលើអនុសញ្ញានេះ។

ធ្វើនៅរ៉ូប៊ីដាម ថ្ងៃទីដប់ ខែកញ្ញា ឆ្នាំមួយពាន់ប្រាំបួនរយកៅសិបប្រាំបី។

## ឧបសម្ព័ន្ធទី I
## គម្រូទការព័ត៌មានសម្រាប់សេចក្តីជូនដំណឹងដោយអនុលោមតាមមាត្រា៥

**សេចក្តីជូនដំណឹងរួមមានៈ**

១-លក្ខណសម្បត្តិ អត្តសញ្ញាណកម្ម និងការប្រើប្រាស់

ក- ឈ្មោះទូទៅ។

ខ- ឈ្មោះគីមីដោយយោងទៅតាមនាមវលីទទួលស្គាល់ជាអន្តរជាតិ(ឧទាហរណ៍ៈ សហភាពអន្តរជាតិនៃភាពសុទ្ធ និងគីមីសាស្ត្រអនុវត្ត(IUPAC))ដែលនាមវលីនេះមាន។

គ- ឈ្មោះពាណិជ្ជកម្មនិងឈ្មោះនៃការរៀបចំផលិត។

ឃ-លេខកូដតាម លេខកូដសង្ខេបសេវាកម្មសារជាតុគីមី(CAS) ឬតាមប្រព័ន្ធសុខដុមនីយកម្ម លេខកូដគយ និងលេខកូដផ្សេងទៀត។

ង- ព័ត៌មានស្តីពីចំណាត់ថ្នាក់គ្រោះថ្នាក់នៅពេលដែលសារជាតុគីមីជាកម្មវត្ថុដែលត្រូវចាត់ថ្នាក់។

ច- ការប្រើប្រាស់សារជាតុគីមី។

ឆ- លក្ខណៈរូបគីមី ភាពពុលវិទ្យា និងភាពពុលវិទ្យាបរិស្ថាន។

២- វិធានការច្បាប់ចុងក្រោយ

ក- ព័ត៌មានជាក់លាក់ស្តីពីវិធានការច្បាប់ចុងក្រោយៈ

១- សេចក្តីសង្ខេបស្តីពីវិធានការច្បាប់ចុងក្រោយ។

២- ឯកសារយោងផ្លូវច្បាប់។

៣- កាលបរិច្ឆេទនៃការចូលជាធរមាននៃវិធានការច្បាប់ចុងក្រោយ។

៤- ការបញ្ជាក់លើវិធានការចុងក្រោយត្រូវបានប្រើលើមូលដ្ឋានហានិភ័យក្នុងការវាយតម្លៃភាពមានគ្រោះថ្នាក់ ហើយប្រសិនបើព័ត៌មាននៃការវាយតម្លៃទាំងនេះ គ្របដណ្តប់ការយោងទៅនឹងឯកសារដែលពាក់ព័ន្ធ។

៥- ហេតុផលដែលបណ្តាលឱ្យមានវិធានការច្បាប់ចុងក្រោយពាក់ព័ន្ធនឹងសុខភាពមនុស្ស រួមមានសុខភាពរបស់កម្មករ និងអ្នកប្រើប្រាស់ ឬបរិស្ថាន។

៦- សេចក្តីសង្ខេបពីហានិភ័យ និង ភាពមានគ្រោះថ្នាក់ទាំងឡាយកើត

ឡើងដោយសារសារធាតុគីមីចំពោះសុខភាពមនុស្ស រួមមានសុខភាពរបស់កម្មករនិងអ្នកប្រើប្រាស់ ឬបរិស្ថានព្រមទាំងប្រសិទ្ធភាពរំពឹងទុកនៃវិធានការច្បាប់ចុងក្រោយ។

ខ- ចំណាត់ថ្នាក់ ឬ បណ្តាចំណាត់ថ្នាក់សារធាតុគីមីដែលវិធានការច្បាប់ចុងក្រោយត្រូវបានអនុវត្តជាមួយនូវចំណាត់ថ្នាក់នីមួយៗរួមមាន៖

១- ការប្រើប្រាស់ឬការប្រើប្រាស់ទាំងឡាយដែលត្រូវបានហាមឃាត់ដោយវិធានការច្បាប់ចុងក្រោយ។

២- ការប្រើប្រាស់ឬការប្រើប្រាស់ទាំងឡាយណាដែលនៅរក្សាការអនុញ្ញាតឱ្យនាំចូល នាំចេញ និងប្រើប្រាស់នៅឡើយ។

៣- ការប៉ាន់ស្មានបរិមាណសារធាតុគីមីដែលបានផលិត នាំចូល នាំចេញ និងប្រើប្រាស់បើមានលទ្ធភាព។

គ- ការបញ្ជាក់ចំពោះលទ្ធភាពពង្រីកនូវវិធានការច្បាប់ចុងក្រោយដូចគ្នាទៅដល់រដ្ឋ និងតំបន់ទាំងឡាយផ្សេងទៀត។

ឃ- ទំនាក់ទំនងព័ត៌មានទាំងឡាយរួមមាន៖

១- ការវាយតម្លៃពីផលប៉ះពាល់ទាំងឡាយទៅលើសេដ្ឋកិច្ចសង្គមនៃវិធានការច្បាប់ចុងក្រោយ។

២- ព័ត៌មានស្តីពីវិធានការជំនួសផ្សេងទៀតនិងទំនាក់ទំនងហានិភ័យរបស់វាដែលមានស្រាប់ដូចជា ៖

- វិធានការចម្រុះនៃការគ្រប់គ្រងសមាសភាពចង្រៃ
- កិច្ចប្រតិបត្តិផ្នែកឧស្សាហកម្ម និង កែច្នៃទាំងឡាយរួមមានបច្ចេកវិទ្យាទំនើបជាដើម។

## ឧបសម្ព័ន្ធទី II
(thieu tuong. TRAN TRONG NGUNG pho tu lenh va tham muu truong QD4)
៩-វរសេនីយ៍ឯក ហូ កុងចាង (dai ta. HO CONG TRANG chu nhiem cuc ky thuat)
១០-វរសេនីយ៍ឯក ង្វៀន កុងហៀន (dai ta. NGUYEN CONG HIEN chu nhiem cuc hau can)
១១-វរសេនីយ៍ឯក វ៉ូ មិញជី (dai ta. VO MINH TRI pho tham muu truong)
១២-វរសេនីយ៍ឯក ផាន កុងលៀម (dai ta. PHAN CONG LIEM truong phong doi ngoai)
១៣-វរសេនីយ៍ឯក វូ ង៉ុកថាំង (dai ta. VU NGOC THANG chanh van phong)
១៤-វរសេនីយ៍ឯក ដូ វ៉ាន់ថាំង (dai ta. DO VAN THANG truong phong quan bao)
១៥-វរសេនីយ៍ឯក វ៉ូ ចុងហេក (dai ta. VO TRONG HE pho tu lenh QD4)
១៦-វរសេនីយ៍ឯក ហ័ង វ៉ាន់ងៀ (dai ta. HOANG VAN NGHIA pho chinh uy QD4)
១៧-វរសេនីយ៍ឯក ផាម ស៊ានចាវ (dai ta. PHAM XUAN TRAO pho tu lenh va tham muu truong QD4)
១៨-វរសេនីយ៍ឯក ចិន ស៊ានជៀន (dai ta. TRAN XUAN CHUYEN chanh van phong QD4)

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ជ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

១-លោក ម៉ា សាម៉ាត
២-លោកស្រី ជៀប ម៉ូរ៉ា
៣-លោក ម៉ាង តារ៉ា
៤-លោក ព្រំ សំអុន
៥-លោក ចាន់ សួង
៦-លោក អ៊ុំ ធុទ្ធី
៧-លោក ចាក់ ប៊ុនធី
៨-លោក ឡេង ដារ៉ា
៩-វរសេនីយ៍ទោ ឆ្មុន សុវណ្ណ ១៦២៤០៦
១០-វរសេនីយ៍ទោ ប៊ិច តុងហេង ០១៩៦៣៣
១១-វរសេនីយ៍ទោ ឡៅ ប៊ុនឆាយ ០៥៦៣៤៧
១២-វរសេនីយ៍ទោ ឈួរ សុខា ១៣៨៦១៧
១៣-លោក ធី សុខពិគន្ធ
១៤-លោក តំណា សម្ផស្ស
១៥-លោក ពក ចាសនា
១៦៣-លោក ម៉ុង ណារិន
១៧-លោក សុខ សុធីរៈ
១៨-លោក លី ពៅ
១៩-លោកស្រី គង់ នៅ
២០-អនុសេនីយ៍ឯក ពេជ្រ សុខអន ០៣២៤១៩

ឋ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

១-លោក ប៉ាត សៀកលី
២-លោក ទៀម សយ
៣-លោក ប្រាក់ សារុំ
៤-លោក អ៊ុំ ចាមរិន
៥-លោក សែន សឿន
៦-លោក ញៀប ប៊ុននាង
៧-លោក ម៉ី ខេត
៨-លោក អែម ឆន
៩-លោក ប៊ិច កាន់
១០-លោក ឃឹម ស៊ុន
១១-លោក មាស សាម៉ុន
១២-លោក ជៃ ឈុំ

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នរកត.១២០៩.៩៤៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២

លេខ: ៨០៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១២

អគ្គលេខាធិការរងទីស្ដីការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៩៤១

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រតនខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការចំនួន ០២ រូប ពីឋានន្តរស័ក្តិវរមន្ត្រី ទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

| ល.រ | គោត្តនាម និងនាម | ភេទ | ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និង ថ្នាក់ | |
|---|---|---|---|---|
| | | | ចាស់ | ថ្មី |
| ១ | ម៉ៅ ធីហុង | ប | វរមន្ត្រីថ្នាក់លេខ ១ | ឧត្តមមន្ត្រីថ្នាក់លេខ ៣ |
| ២ | ម៉ៅ កេង | ប | វរមន្ត្រីថ្នាក់លេខ ២ | ឧត្តមមន្ត្រីថ្នាក់លេខ ៤ |

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧.ក.ក. ១២០៩.៥៤៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២*

លេខៈ ៧៩៨ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល
[illegible] សុខា

ច្បាប់ចម្លង

# KRET

NS / KRT / 0912 / ៨៤២

*Nous*

*Preah Karuna Preah Bat Samdech*

*Preah Boromneath Norodom Sihamoni*

*Roi du Cambodge*

**NOMMONS**

*à titre posthume*

*Monsieur Peter Ehrenhaft,*

*Grand Officier de l'Ordre Royal du Sahamétrei,*

*en témoignage de Notre très haute considération.*

Norodom Sihamoni

តារាង. ១២០៩.៤៤៩

បានប្រថាប់ព្រះរាជលញ្ឆករហើយ

*Fait au Palais Royal, le* 19 *Septembre 2012*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

លេខ ...៨៣.../...១២...រ.ចច

រាជធានីភ្នំពេញ ថ្ងៃទី ...០៤... ខែ ...តុលា... ឆ្នាំ ...២០១២

សម្តេចចៅហ្វាវាំង [illegible] អធិបតី[illegible] គង់ សំអុល

ឧបនាយករដ្ឋមន្ត្រី [illegible] រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ROYAUME DU CAMBODGE — MINISTÈRE DU PALAIS ROYAL

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៩៤៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការនិងសប្បុរសជន ចំនួន៧៩រូប ដែលមានគុណបំណាច់និងស្នាដៃល្អក្នុងការ
ចូលរួមកសាងអភិវឌ្ឍន៍សមិទ្ធផលនានា នៅក្នុងខេត្តព្រះសីហនុ កន្លងមក

**នូវ**

**ក-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍**

១-លោក ក្រូចក់ ស៊ីមារ៉ា
២-លោក ជិន សារិន
៣-ឧត្តមសេនីយ៍ត្រី ម៉ៅង និន អត្តលេខ ០០០៣០៥
៤-លោក សំអុល ឆារិទ្ធ
៥-ឯកឧត្តម និត ហ៊ើល
៦-លោក ខេង គេង

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**

១-លោក ចុណ្ណ យុទ្ធា
២-អ្នកស្រី នួន ច៊ុនណា
៣-លោក ចាន់ កុលបុត្រ
៤-លោក វង្ស សារ៉ាត
៥-លោក សុខ ផន
៦-លោក សន កុសល

**គ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍**

១-ឧកញ៉ា សុខ សុខា
២-ឯកឧត្តម នួន ប៉ុក
៣-លោក ទេព ថិរសិដ្ឋ
៤-លោក និត ទុទ្ធី

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

១-វរសេនីយ៍ឯកឡៅម ស៊ីមន អត្តលេខ ០០១៣៩០
២-លោក សេង ត្រី
៣-លោក កែវ ឡាយ
៤-លោក ស្រ៊ុន ច៊ិនថាត
៥-វរសេនីយ៍ទោកែវ សុផល អត្តលេខ ០០៣១៩៣
៦-វរសេនីយ៍ត្រី លី ឃួត អត្តលេខ ០៣៧៣២៦
៧-លោក ឯម គាព
៨-លោក កាន់ ណារិទ្ធ
៩-ឯកឧត្តម ជា សោម
១០-លោក ឆាន សារុំ
១១-លោក ម៉េន ចុល្លីណា
១២-លោកស្រី ម៉ម ច៊ិនថា

**ង-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា**

១-លោកជំទាវ កែវ សុផល នួន ប៉ុក
២-លោកជំទាវ ចាន់ លាង សុខ សុខា
៣-លោក ហួយ ណារិទ្ធ
៤-លោក ជិន ចន្ធី
៥-អ្នកស្រី សេង ផល្លី
៦-លោក គង់ សារឿន
៧-អ្នកស្រី ហៀក ហ៊ីមល្លី

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

១-លោក ឡាយ សុគន្ធ
២-លោក អេង ផា
៣-លោក ឌឹម ទី
៤-លោក សេក សាវ៉ុន
៥-លោក សោម នាយ៉ា

ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

១-អ្នកស្រី យ៉ឹង សុឃឿន
២-លោក ឌិត សុជាតិ
៣-លោក គ្រី ប៊ុនថា
៤-លោក គួន វង្ស
៥-អនុសេនីយ៍ឯក ហ៊ិត សីហា អត្តលេខ ០៤៦៩១០
៦-លោក ម៉ាក់ សន
៧-លោក ស៊ាង ចាន់
៨-លោក កុក សំអ៊ាន
៩-លោក សេង សោភ័ណ្ឌ
១០-លោក ខឹម សារ៉ុន
១១-លោក តូច បូរិន្ទ
១២-លោក ស្មោង ពៅ
១៣-លោក សារ៉ាត ចំនួទីរះ

ជ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សប្ញទ្ធិ

១-លោក សន រិទ្ធី
២-កញ្ញា សន រស្មី
៣-លោក យ៉ាន ប៊ុននឿន
៤-លោក ស៊ាន ពុធ
៥-លោក ឆាន សារ៉េត
៦-លោក ប្រាក់ សុវណ្ណ
៧-លោក ប៊ុក ថូង
៨-លោក ហាស់ សេណាតូ
៩-លោក សំអុល តាំងប៊ុនណាត
១០-លោក ជួន ភារុណា
១១-អ្នកស្រី យន រតនាថ
១២-លោក ខេង សីហា
១៣-លោក អ៊ូ ជោត
១៤-លោក ឡាយ ប៊ុនផា
១៥-លោក ព្រុំ បូណា
១៦-លោក ទេព ណាប់
១៧-លោកស្រី នាង ស៊ីវឡានា
១៨-លោក ហាក់ សុខរិទ្ធ
១៩-លោក អូន ណារិទ្ធ
២០-លោក ឆេង លាងស្រ៊ុន
២១-កញ្ញា ថាវ ឈីវលី
២២-កញ្ញា រ៉ាន់ ស្រីរត្ន
២៣-លោក ហែម ហ៊ីម៉ាធារិទ្ធ
២៤-លោក អ៊ិន មេត្តា
២៥-លោក ទេព ស៊ីណូរ៉ា
២៦-លោក ហម ប៊ុនហៀង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារស.១២០៩.៥៤០

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១២

លេខៈ ៤២៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥៥ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការបង្កើតតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខនស/រកម/១២៩៦/៣៤ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីតំបន់ដីសើមមានសារៈសំខាន់ជាអន្តរជាតិ ពិសេសជាទីជម្រកសត្វស្លាបទឹក ចុះនៅទីក្រុងរ៉ាំសា ប្រទេសអ៊ីរ៉ង់ នាថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៧១
- បានឃើញព្រះរាជក្រមលេខនស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខនស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៥ អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មការអភិរក្សនិងអភិវឌ្ឍន៍តំបន់ទេសចរណ៍សត្វផ្សោតទន្លេមេគង្គ
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១២៣ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការកំណត់ប្រភេទផល ផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១២

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងបង្កើតតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ ដែលជារតនសម្បត្តិធម្មជាតិមានជីវិតដ៏ពិសិដ្ឋ ជាពិសេសសម្រាប់បម្រើវិស័យអេកូទេសចរណ៍ និងអភិរក្សសត្វផ្សោតប្រកបដោយនិរន្តរភាព។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅ៖

- ការពារ អភិរក្សសត្វផ្សោតទន្លេមេគង្គ ដែលជិតផុតពូជ ដោយកាត់បន្ថយអត្រាស្លាប់ឲ្យនៅក្នុងកម្រិតអប្បបរមា និងបង្កលក្ខណៈអំណោយផលដល់ការបន្តពូជពង្សរបស់ថនិកសត្វនេះ

- ការពារនិងថែរក្សាលំនឹងមជ្ឈដ្ឋានធម្មជាតិនិងគុណភាពទឹកឲ្យមានប្រក្រតីភាពសម្រាប់ធានាការរីកលូតលាស់នៃជីវសាស្ត្រចម្រុះដែលទ្រទ្រង់ការរស់នៅរបស់សត្វផ្សោត
- គាំទ្រការអភិវឌ្ឍអេកូទេសចរណ៍សត្វផ្សោតទន្លេមេគង្គរបស់សហគមន៍មូលដ្ឋាន ដែលមិនបង្កផលប៉ះពាល់ ជាអវិជ្ជមានដល់និរន្តរភាពសត្វផ្សោត ដើម្បីការអភិវឌ្ឍសង្គមសេដ្ឋកិច្ចជនបទនិងការកាត់បន្ថយភាពក្រីក្រ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ៣.-**

តំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

## ជំពូកទី៣
## ការកំណត់តំបន់

**មាត្រា ៤.-**

តំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គលាតសន្ធឹងតាមដងទន្លេមេគង្គភាគខាងជើង ក្នុងកំណាត់ខាងលើប្រវែង១៨០គីឡូម៉ែត្រ ចាប់ពីខ្សែបន្ទាត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចំណុចល្បាក់ខោនទឹកធ្លាក់ព្រះនិមិត្ត-អន្លង់ឈើទាល-អន្លង់មរកត ក្នុងខេត្តស្ទឹងត្រែង មកទល់នឹងក្បាលកោះទ្រង់ក្នុងក្រុងក្រចេះ ខេត្តក្រចេះ មានទំហំ៧៧៦,៣០គីឡូម៉ែត្រការ៉េ ដោយមិនគិតបញ្ចូលតំបន់ដីសើមមានសារៈសំខាន់ជាអន្តរជាតិពិសេសជាទីជម្រកសត្វស្លាបទឹក ខេត្តស្ទឹងត្រែងទំហំ១៤៦គីឡូម៉ែត្រការ៉េ ដែលបានចុះក្នុងបញ្ជីនៃអនុសញ្ញារ៉ាំសា ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១នៃអនុក្រឹត្យនេះ។

**មាត្រា ៥.-**

ទំហំនិងព្រំប្រទល់តំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គដូចមានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ អាចធ្វើការកែប្រែតាមការចាំបាច់ ដោយផ្អែកលើមូលដ្ឋានសិក្សាសេដ្ឋកិច្ចវិទ្យាសាស្ត្រ។ ការកែប្រែនេះត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៤
## ការចាត់ថ្នាក់និងការគ្រប់គ្រង

**មាត្រា ៦.-**

តំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គដែលលាតសន្ធឹងតាមដងទន្លេមេគង្គផ្នែកខាងលើប្រវែង ៩៥គីឡូម៉ែត្រ ក្នុងខេត្តស្ទឹងត្រែងនិងប្រវែង៨៥គីឡូម៉ែត្រ ក្នុងខេត្តក្រចេះ ត្រូវបានបែងចែកជាតំបន់ស្នូលនិង

តំបន់ទ្រនាប់ ដោយផ្អែកទៅតាមវត្តមាន ទម្លាប់រស់នៅ និងការផ្លាស់ប្តូរទីកន្លែងរបស់សត្វផ្សោតតាមរដូវកាលនីមួយៗ៖

**ក- នៅរដូវប្រាំង** ចាប់ពីដើមខែវិច្ឆិកា ដល់ចុងខែឧសភាឆ្នាំបន្ទាប់ តំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គត្រូវបានបែងចែកជាតំបន់ស្នូលចំនួន៨កន្លែងនិងតំបន់ទ្រនាប់ចំនួន៨កន្លែង៖

**១- តំបន់ស្នូល**

តំបន់ស្នូលគឺជាកន្លែងបន្តពូជពង្សដ៏ពិសិដ្ឋជាពិសេសរបស់សត្វផ្សោតទន្លេមេគង្គ ហើយក៏ជាតំបន់ទឹកជ្រៅសម្បូរទៅដោយផ្ទាំងថ្មរកេតរកូត ព្រៃលិចទឹក តំបន់ដុះសារាយខ្មៅ ឆ្នេរខ្សាច់ និងអន្លង់ជ្រៅៗ ដែលជាកន្លែងបន្តពូជពង្សធម្មជាតិដ៏ពិសិដ្ឋរបស់ប្រភេទត្រីសប្តត្រីទន្លេនិងប្រភេទត្រីប្រចាំតំបន់។

- **តំបន់ស្នូលទី១** ស្ថិតនៅក្នុងឃុំព្រះរំកិលនិងឃុំអូរស្វាយ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ ជាកំណាត់ទន្លេដែលព្រំប្រទល់ខាងជើងកំណត់ដោយខ្សែបន្ទាត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវចំណុចអន្លង់ឈើទាល-អន្លង់មរកតនិងព្រំប្រទល់ខាងត្បូងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់បណ្តាចំណុច A4 ទៅ A5 ដែលមាននិយាមកា៖

  A4 ( ៦០៤៧៥១-១៥៣៥៩៥៣)  A5 ( ៦០៨៩៥៩-១៥៣៦២៨៨ )។

- **តំបន់ស្នូលទី២** ស្ថិតនៅក្នុងស្រុកសៀមបូក ខេត្តស្ទឹងត្រែងនិងស្រុកសំបូរ ខេត្តក្រចេះ មានផ្ទៃទឹកទំហំ១២២,២៧គីឡូម៉ែត្រការ៉េ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ៣នៃអនុក្រឹត្យនេះ ជាកំណាត់ទន្លេដែលមានព្រំប្រទល់ខាងជើងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីក្បាលកោះស្រឡាយ ទៅចំណុច B និង B1 ត្រង់កន្លែងទឹកជ្រៅកាំងមេម៉ាយ មាននិយាមកា៖

  B ( ៥៩៩៧១៥-១៤៨៩៣២៣ )  B1 ( ៦០១៩៦១-១៤៨៩៤៩០ )

  និងព្រំប្រទល់ខាងត្បូងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច B2 ទៅ B3 ដែលមាននិយាមកា៖

  B2 ( ៦១៤៥០០-១៤៤៨៤៥៩ )  B3 ( ៦០៩៦៦៨-១៤៥២២៦៥ )។

- **តំបន់ស្នូលទី៣** ស្ថិតនៅក្នុងឃុំកំពង់ចាម ឃុំសំបូរ និងឃុំវឌ្ឍនៈ ស្រុកសំបូរ ខេត្តក្រចេះ មានផ្ទៃទឹកទំហំ៦០,៩០គីឡូម៉ែត្រការ៉េ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ៤នៃអនុក្រឹត្យនេះ ជាកំណាត់ខ្នែងទន្លេធំជាងគេ ដែលព្រំប្រទល់ខាងជើងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច C ទៅ C1 ត្រង់កន្លែង កាំងកោះព្រាង មាននិយាមកា៖

  C ( ៦០៧២៣៦-១៤៣៣៥៣៤ )  C1 ( ៦០៩២៥៨-១៤៣៣៦០២ )

  និងព្រំប្រទល់ខាងកើតកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច C2 ទៅ C3 មាននិយាមកា៖

  C2 ( ៦០៣៩៩០-១៤១៥៩៦៩ )  C3 ( ៦០៥៧៣៣-១៤១៣៦៧៦ )

  ហើយនិងព្រំប្រទល់ខាងត្បូងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច C4 ទៅ C5 មាននិយាមកា៖

  C4 ( ៦០៩៤៨០-១៤០៦៥៣០ )  C5 ( ៦០៧០៥១-១៤០៣៧៧៨ )។

**តំបន់ស្នូលទី៤** ស្ថិតនៅក្នុងឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វនិងឃុំសំបុក ឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ មានផ្ទៃទឹកទំហំ២១,៦៥គីឡូម៉ែត្រការ៉េ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ៥នៃអនុក្រឹត្យនេះ ជាកំណាត់ទន្លេដែលមានព្រំប្រទល់ខាងជើងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច D ទៅ D1 មាននិយាមកា ៖

D(៦០៧៣១៨-១៣៩៥៥០២) D1(៦១១៣៧៨-១៣៩៥៥៤៧)

និងព្រំប្រទល់ខាងត្បូងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច D2 ទៅ D3 ចំក្បាលកោះទ្រង់ មាននិយាមកា៖

D2(៦០៩៥៣៨-១៣៨៤២២៥) D3(៦០៧២៤៧-១៣៨៤២៩០)។

**២- តំបន់ទ្រនាប់**

តំបន់ទ្រនាប់ គឺជាជម្រករដូវប្រាំងដ៏ពិសិដ្ឋរបស់ពពួកមេពូជត្រីសប្បត្រីទន្លេនិងប្រភេទត្រីប្រចាំតំបន់ ដែលទម្លាប់មកសំងំលាក់ខ្លួនដើម្បីវិវឌ្ឍក្រពេញបន្តពូជ។ ជាទូទៅ តំបន់នេះសម្បូរទៅដោយផ្ទាំងថ្មរកេតរកូត ព្រៃលិចទឹក កន្លែងដុះសារាយខ្មៅជាចំណីបន្ថែមរបស់ត្រីមេពូជ អន្លង់ជ្រៅៗ និងឆ្នេរខ្សាច់។

- **តំបន់ទ្រនាប់ទី១** ស្ថិតនៅក្នុងភូមិសាស្ត្រឃុំព្រះរំកិល ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង មានផ្ទៃទឹកលាតសន្ធឹងរវាងដីគោកនិងខ្សែបន្ទាត់ព្រំដែនទឹកនៃព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចាប់ពីចំណុចល្បាក់ខោនទឹកធ្លាក់ព្រះនិមិត្ត ត្រង់ព្រំប្រទល់ខេត្តព្រះវិហារនិងខេត្តស្ទឹងត្រែង មកទល់ចំណុចកែងភូមិអន្លង់ស្វាយ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។
- **តំបន់ទ្រនាប់ទី២** ស្ថិតនៅក្នុងភូមិសាស្ត្រឃុំព្រះរំកិល ឃុំអូរស្វាយ ឃុំថាឡាបរិវ៉ាត់ ឃុំអូរី និងឃុំកាំងចាម ស្រុកថាឡាបរិវ៉ាត់និងសង្កាត់សាមគ្គី សង្កាត់ព្រះបាទ ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង មានផ្ទៃទឹកទំហំ១៥៣,៨៣គីឡូម៉ែត្រការ៉េ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ៣នៃអនុក្រឹត្យនេះ ជាកំណាត់ទន្លេ ដែលព្រំប្រទល់ខាងជើងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច A4 ទៅ A5 និងព្រំប្រទល់ខាងត្បូងកំណត់ដោយខ្សែបន្ទាត់ពីចំណុច B ទៅ B1 ដោយមិនគិតបញ្ចូលតំបន់ដីសើមជាជម្រកសត្វស្លាបទឹកខេត្តស្ទឹងត្រែងទំហំ១៤៦គីឡូម៉ែត្រការ៉េ។
- **តំបន់ទ្រនាប់ទី៣** ស្ថិតនៅក្នុងឃុំអូរគ្រៀង ឃុំកោះខ្ញែ ឃុំបឹងចារ និងឃុំសំបូរ ស្រុកសំបូរ ខេត្តក្រចេះ មានផ្ទៃទឹកទំហំ២២៦,៨៤គីឡូម៉ែត្រការ៉េ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ៤នៃអនុក្រឹត្យនេះ ជាកំណាត់ខ្នែងទន្លេតូចៗខាងកើត ដែលមានព្រំប្រទល់ខាងជើងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច B2 ទៅ B3 ព្រំប្រទល់ខាងត្បូងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច C ទៅ C1 និងព្រំប្រទល់ខាងត្បូងឆៀងខាងកើតកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច C2 ទៅ C3។
- **តំបន់ទ្រនាប់ទី៤** គ្របដណ្តប់លើមួយផ្នែកនៃតំបន់កោះមួយពាន់ ស្ថិតនៅក្នុងឃុំសំបូរ ឃុំសណ្តាន់ ឃុំវឌ្ឍនៈ ស្រុកសំបូរនិងឃុំសំបុក ស្រុកចិត្របុរី ក្នុងខេត្តក្រចេះ មានផ្ទៃទឹកទំហំ៣០,១៤គីឡូម៉ែត្រការ៉េ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ៥នៃអនុក្រឹត្យនេះ ជាកំណាត់ទន្លេដែលមានព្រំប្រទល់ខាង

ជើងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច C4 ទៅ C5 និងព្រំប្រទល់ខាងត្បូងកំណត់ដោយខ្សែបន្ទាត់ភ្ជាប់ពីចំណុច D ទៅ D1។

**ខ- នៅរដូវវស្សា ចាប់ពីដើមខែមិថុនា ដល់ចុងខែតុលា** ផ្ទៃទឹកទាំងអស់នៃតំបន់ការពារសត្វផ្សោតទន្លេមេគង្គទំហំ៣៨៩,៥០គីឡូម៉ែត្រការ៉េ ត្រូវកំណត់ជាតំបន់ស្នូលរដូវវស្សា ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ៦នៃអនុក្រឹតនេះ ក្នុងនោះតំបន់ដីសើមមានសារៈសំខាន់ជាអន្តរជាតិពិសេសជាទីជម្រកសត្វស្លាបទឹក ខេត្តស្ទឹងត្រែង ទំហំ១៤៦គីឡូម៉ែត្រការ៉េ ត្រូវស្ថិតនៅ ក្រោមការគ្រប់គ្រងដោយឡែករបស់ក្រសួងបរិស្ថាន។

ផ្ទៃដីកោះទាំងអស់នៅក្នុងតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ ទាំងនៅក្នុងតំបន់ស្នូលរដូវប្រាំង ទាំងនៅក្នុងតំបន់ស្នូលរដូវវស្សាមានទំហំ៣៨៦,៨០គីឡូម៉ែត្រការ៉េ ត្រូវកំណត់ជាតំបន់ទ្រនាប់។

## មាត្រា ៧.-

ត្រូវចាត់វិធានការជាអាទិ៍តាមរយៈការអប់រំបណ្តុះបណ្តាលក្នុងគោលបំណងហាមឃាត់ដូចខាងក្រោម៖

- ការធ្វើនេសាទដោយឧបករណ៍មងគ្រប់ប្រភេទក្នុងតំបន់ស្នូលរដូវប្រាំងនិងរដូវវស្សា
- ការតាំងលំនៅជាផ្ទះទឹក ឬផ្ទះលើទូកនៅក្នុងតំបន់ស្នូលរដូវប្រាំង
- ការធ្វើវារីវប្បកម្មបែបឬស៊ងក្នុងតំបន់ស្នូលរដូវប្រាំង
- ការធ្វើនាវាចរណ៍ដោយប្រើជលយានយន្តដែលមានល្បឿនលើសពី៣០គីឡូម៉ែត្រឬ២០ម៉ៃក្នុងមួយម៉ោង នៅក្នុងតំបន់ស្នូលរដូវប្រាំង
- ការប្រើប្រាស់ស្រឡាងដែលអាចចម្លងរថយន្តលើសពីបួនគ្រឿងឡើងទៅក្នុងតំបន់ស្នូលរដូវប្រាំង
- ការកាប់ឆ្ការព្រៃឬការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅតាមបណ្តាកោះក្នុងតំបន់ការពារសត្វផ្សោតជាទ្រង់ទ្រាយធំដើម្បីបម្រើផលប្រយោជន៍ឯកជន។

អាចអនុញ្ញាត៖

- ការធ្វើនេសាទដោយប្រើឧបករណ៍មងក្រឡាតូចជាង៤សង់ទីម៉ែត្រឬ៤ហ៊ុន ដែលមានម្ចាស់ឬអ្នកនេសាទនៅឃ្លាំមើល នៅក្នុងតំបន់ទ្រនាប់រដូវប្រាំង
- ការសិក្សាស្រាវជ្រាវសេដ្ឋកិច្ចវិទ្យាសាស្ត្រ ការអភិវឌ្ឍអេកូទេសចរណ៍ ការអភិវឌ្ឍកសិកម្ម និងការដឹកជញ្ជូនឆ្លងកាត់ របស់ប្រជាពលរដ្ឋមូលដ្ឋាននៅក្នុងតំបន់ស្នូលនិងតំបន់ទ្រនាប់ ទាំងអស់
- ការនេសាទដោយឧបករណ៍នេសាទគ្រួសារមានដូចជា សំណាញ់ សន្ទូចផ្លែមួយ ចាន់ លប ទ្រូ ឈ្នាងត្រាំ សៃយ៉ឺនឫស្សី និងថ្នងដែលគ្មានឧបករណ៍រួមផ្សំ នៅក្នុងតំបន់ស្នូលនិងតំបន់ទ្រនាប់។

## មាត្រា ៨.-

រដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ត្រូវសកម្មចូលរួមសហការ ដោយជួយផ្តល់មន្ត្រីក្រោមឱវាទនិងជួយលើកទឹកចិត្តពលរដ្ឋក្នុងមូលដ្ឋានឲ្យស្ម័គ្រចិត្តចូលរួមក្នុងក្រុមឆ្មាំទន្លេ ដើម្បីគ្រប់គ្រងតំបន់ការពារសត្វផ្សោតទន្លេមេគង្គជាប្រចាំប្រកបដោយប្រសិទ្ធភាពខ្ពស់ តាមសំណើរបស់ស្ថាប័នមានសមត្ថកិច្ច។

អាជ្ញាធរមានសមត្ថកិច្ចត្រូវរៀបចំបោះបង្គោលសញ្ញាសម្គាល់ព្រំប្រទល់តំបន់ស្នូលនិងតំបន់ទ្រនាប់ ទាំងនៅលើដីគោក ទាំងនៅក្នុងទឹកនិងផែនទីដែលបញ្ជាក់ពីបទបញ្ជាដែលតម្រូវឲ្យអ្នកពាក់ព័ន្ធគោរពអនុវត្តតាម។

## ជំពូកទី៥
## ទោសប្បញ្ញត្តិ

**មាត្រា ៩.-**

ជនណាដែលប្រព្រឹត្តផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១.-**

អនុក្រឹត្យនេះនិងដែនទីឧបសម្ព័ន្ធមិនពាក់ព័ន្ធនឹងបញ្ហាព្រំដែនរវាងប្រទេសនិងប្រទេសទេ។

**មាត្រា ១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ប្រធានគណៈកម្មការអភិរក្សនិងអភិវឌ្ឍន៍តំបន់ទេសចរណ៍សត្វផ្សោតទន្លេមេគង្គ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តក្រចេះនិង អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ១នៃអនុក្រឹត្យលេខ ១៩៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០១២**

**ស្តីពីការបង្កើតតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ ( ទំហំ ៧៧៦,៣ គ.ម២ ) ខេត្តស្ទឹងត្រែងនិងខេត្តក្រចេះ**







Coordinate System
Projection: UTM
Zone: 48 N
Spheroid: Everest
Datum : Indian 1960
Units : Kilometers
រៀបចំដោយរដ្ឋបាលជលផល

**និមិត្តសញ្ញាសម្គាល់**

- ចំណុចសម្គាល់និយាមកា
- តំបន់គ្រប់គ្រង និងការពារសត្វផ្សោតទន្លេមេគង្គ (ផ្ទៃដីសរុប= ៧៧៦,៣គម២)
- ផ្ទៃទឹក (៣៨៩,៨ គម២)
- ផ្ទៃដីគោក (៣៨៦,៦ គម២)

ព្រំប្រទល់រដ្ឋបាល
- ទីរួមឃុំ
- ទីរួមស្រុក
- ទីរួមខេត្ត
- ព្រំប្រទល់ឃុំ
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ខេត្ត

0 10 20 40 Kilometers

**បានឃើញនិងឯកភាព**
**រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ២០១២**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** | **រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អ៊ឹម ឈុនលឹម** | ចាន់.សារុន

**ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០១២**

**ស្តីពីការបង្កើតតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ (តំបន់ស្នូលទី១ ទំហំ ១៥,២៦ គ.ម² និងតំបន់ទ្រនាប់ទី១ ទំហំ ១,៥៥ គ.ម²) ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង**




## និមិត្តសញ្ញាសម្គាល់

- ចំណុចសម្គាល់និយាមកា
- តំបន់ស្នូលទី១
- តំបន់ទ្រនាប់ទី១
- ផ្ទៃទឹក
- ផ្ទៃដីគោក

**ព្រំប្រទល់រដ្ឋបាល**

- ទីរួមភូមិ
- ទីរួមឃុំ
- ទីរួមស្រុក
- ទីរួមខេត្ត
- ព្រំប្រទល់ឃុំ
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ខេត្ត

Coordinate System
Projection: UTM
Zone: 48 N
Spheroid: Everest
Datum : Indian 1960
Units : Kilometers
រៀបចំដោយរដ្ឋបាលជលផល

**តារាងបង្ហាញផ្ទៃដីតំបន់ស្នូលទី១ និងតំបន់ទ្រនាប់ទី១ (គ.ម²)**

| | ផ្ទៃដីគោក | ផ្ទៃទឹក | ផ្ទៃដីសរុប |
|---|---|---|---|
| តំបន់ទ្រនាប់ទី១ | ០ | ១,៥៥ | ១,៥៥ |
| តំបន់ស្នូលទី១ | ៥,២៨ | ៩,៩៨ | ១៥,២៦ |

បានឃើញនិងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ២០១២
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អ៊ឹម ឈុនលឹម
ចាន់ សារុន

**ឧបសម្ព័ន្ធ៣នៃអនុក្រឹត្យលេខ ១៩៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០១២**

**ស្តីពីការបង្កើតតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ (តំបន់ស្នូលទី២ ទំហំ ២៦០,៥៦ គ.ម² និងតំបន់ទ្រនាប់ទី២ ទំហំ ១៥៣,៨៣ គ.ម²) ខេត្តស្ទឹងត្រែងនិងខេត្តក្រចេះ**




**និមិត្តសញ្ញាសម្គាល់**

- ចំណុចសម្គាល់និយាមកា
- តំបន់ស្នូលទី២
- តំបន់ទ្រនាប់ទី២
- ផ្ទៃទឹក
- ផ្ទៃដីគោក

**ព្រំប្រទល់រដ្ឋបាល**

- ទីរួមឃុំ
- ទីរួមស្រុក
- ទីរួមខេត្ត
- ព្រំប្រទល់ឃុំ
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ខេត្ត

Coordinate System
Projection: UTM
Zone: 48 N
Spheroid: Everest
Datum : Indian 1960
Units : Kilometers
រៀបចំដោយរដ្ឋបាលជលផល

**តារាងបង្ហាញផ្ទៃដីតំបន់ស្នូលទី២ និងតំបន់ទ្រនាប់ទី២ (គ.ម²)**

| | ផ្ទៃដីគោក | ផ្ទៃទឹក | ផ្ទៃដីសរុប |
|---|---|---|---|
| តំបន់ទ្រនាប់ទី២ | ៧៣,១៦៥ | ៨០,៦៦ | ១៥៣,៨ |
| តំបន់ស្នូលទី២ | ១៣៥,១១ | ១២៥,៤ | ២៦០,៥៦ |

**បានឃើញនិងឯកភាព**

**រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ២០១២**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** **រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អ៊ឹម ឈុនលឹម** ចាន់ សារុន

**ឧបសម្ព័ន្ធ៤នៃអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០១២**
**ស្តីពីការបង្កើតតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ (តំបន់ស្នូលទី ៣ ទំហំ ៦៤,៧៤ គ.ម² និងតំបន់ទ្រនាប់ទី ៣ ទំហំ ២២៦,៨៤ គ.ម²) ស្រុកសំបូរ ខេត្តក្រចេះ**




**និមិត្តសញ្ញាសម្គាល់**

- ចំណុចសម្គាល់និយាមកា
- តំបន់ស្នូលទី៣
- តំបន់ទ្រនាប់ទី៣
- ផ្ទៃទឹក
- ផ្ទៃដីគោក

**ព្រំប្រទល់រដ្ឋបាល**

- ទីរួមភូមិ
- ទីរួមឃុំ
- ទីរួមស្រុក
- ទីរួមខេត្ត
- ព្រំប្រទល់ឃុំ
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ខេត្ត

Coordinate System
Projection: UTM
Zone: 48 N
Spheroid: Everest
Datum : Indian 1960
Units : Kilometers
រៀបចំដោយរដ្ឋបាលជលផល

**តារាងបង្ហាញផ្ទៃដីតំបន់ស្នូលទី៣ និងតំបន់ទ្រនាប់ទី៣ (គ.ម²)**

| | ផ្ទៃដីគោក | ផ្ទៃទឹក | ផ្ទៃដីសរុប |
|---|---|---|---|
| តំបន់ទ្រនាប់ទី៣ | ១៦៥,៦៩ | ៦១,១៥ | ២២៦,៨៤ |
| តំបន់ស្នូលទី៣ | ៣,៩២ | ៦០,៨២ | ៦៤,៧៤ |

បានឃើញនិងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ២០១២

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
**អ៊ឹម ឈុនលឹម**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
**ជ័ន សារុន**

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០១២
ស្តីពីការបង្កើតតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ (តំបន់ស្នូលទី ៤ ទំហំ ២៣,០២ គ.ម² និងតំបន់ទ្រនាប់ទី ៤ ទំហំ ៣០,១៤ គ.ម²) ខេត្តក្រចេះ




និមិត្តសញ្ញាសម្គាល់
- ចំណុចសម្គាល់និយាមកា
- តំបន់ស្នូលទី៤
- តំបន់ទ្រនាប់ទី៤
- ផ្ទៃទឹក
- ផ្ទៃដីគោក

ព្រំប្រទល់រដ្ឋបាល
- ទីរួមភូមិ
- ទីរួមឃុំ
- ទីរួមស្រុក
- ទីរួមខេត្ត
- ព្រំប្រទល់ឃុំ
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ខេត្ត

Coordinate System
Projection: UTM
Zone: 48 N
Spheroid: Everest
Datum : Indian 1960
Units : Kilometers
រៀបចំដោយរដ្ឋបាលជលផល

តារាងបង្ហាញផ្ទៃដីតំបន់ស្នូលទី៤ និងតំបន់ទ្រនាប់ទី៤ (គ.ម²)

| | ផ្ទៃដីគោក | ផ្ទៃទឹក | ផ្ទៃដីសរុប |
|---|---|---|---|
| តំបន់ទ្រនាប់ទី៤ | ២,០៨ | ២៨,០៦ | ៣០,១៤ |
| តំបន់ស្នូលទី៤ | ១,៥៨ | ២១,៤៤ | ២៣,០២ |

បានឃើញនិងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ២០១២

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អ៊ឹម ឈុនលឹម

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ចន្ទ សារុន

**ឧបសម្ព័ន្ធ១នៃអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០១២**
**ស្តីពីការបង្កើតតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ (តំបន់ស្នូលជម្រកផ្សោត មិថុនា - វិច្ឆិកា ទំហំ ៣៨៥,៥ គ.ម²) ខេត្តស្ទឹងត្រែងនិងខេត្តក្រចេះ**



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់វិទ្យាស្ថានអាស៊ី កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សម្រេច

**មាត្រា ១.-**

ទទួលស្គាល់វិទ្យាស្ថានអាស៊ី កម្ពុជា ដែលមានអក្សរកាត់ "វ.អ.ក" និងជាភាសាអង់គ្លេសថា "Asian Institute of Cambodia" ដែលមានអក្សរកាត់ "A.I.C" ។ វិទ្យាស្ថាននេះស្ថិតក្រោមការគ្រប់គ្រងរបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានទីតាំងស្ថិតនៅផ្លូវលេខ៧៣ ភូមិដូនជ្រាំ សង្កាត់ ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ។

**មាត្រា ២.-**

វិទ្យាស្ថានអាស៊ី កម្ពុជា មានភារកិច្ចធ្វើការបណ្តុះបណ្តាល ៖

- ថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង៦០ក្រេឌីត
- ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ សិក្សារយៈពេលយ៉ាងតិច៤ឆ្នាំ ត្រូវនឹង១២០ក្រេឌីត។

**មាត្រា ៣.-**

ចំពោះមុខវិទ្យាស្ថានអាស៊ី កម្ពុជា មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យផែនការ និងហិរញ្ញវត្ថុ
- ការិយាល័យសិក្សា
- មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសាបរទេស
- មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម
- មហាវិទ្យាល័យកសិកម្ម
- មហាវិទ្យាល័យនីតិសាស្ត្រ
- មហាវិទ្យាល័យវិស្វកម្មសំណង់
- មហាវិទ្យាល័យវិស្វកម្មអគ្គិសនី និងអេឡិចត្រូនិច

នៅថ្ងៃអនាគតវិទ្យាស្ថាននេះ អាចបើកសាខា ឬមហាវិទ្យាល័យ ឬឯកទេសផ្សេងទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ៤.-**

លក្ខខណ្ឌទទួលសិស្ស-និស្សិតឲ្យចូលរៀន ៖

- ថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង បេក្ខជនមានសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ ឬបានប្រឡងជាប់ ឬធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។
- ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ បេក្ខជនមានសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។

វិទ្យាស្ថានត្រូវគោរពតាមបទដ្ឋាននានារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលកំណត់អំពីការជ្រើសរើស ការបណ្តុះបណ្តាល ការប្រឡងបញ្ចប់ការសិក្សារបស់សិស្ស-និស្សិត។

**មាត្រា ៥**.-

វិទ្យាស្ថានអាស៊ីកម្ពុជា មាននាយកមួយរូប និងមាននាយករងមួយចំនួនជាជំនួយការតាមការចាំបាច់។ វិទ្យាស្ថានត្រូវធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឲ្យបានទៀងទាត់តាមការកំណត់។

**មាត្រា ៦**.-

សិស្ស-និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថាននេះ និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលបានសញ្ញាបត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឲ្យដោយវិទ្យាស្ថានអាស៊ី កម្ពុជា នឹងត្រូវបានទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះ បានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ៧**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងនាយកវិទ្យាស្ថានអាស៊ី កម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម និងលោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- សាលាខេត្តក្រចេះ
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ..១៥៨...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩, ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ២៨៧ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១**: ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន១៧ ៦០៧ ០០០ ០០០រៀល ពីជំពូក០៩(ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក៦២(សេវាខាងក្រៅផ្សេងៗ) ចំនួន១ ៣៨០ ០០០ ០០០ រៀល ជំពូក៦៣(ពន្ធនិងអាករ) ចំនួន១០ ០០០ ០០០ ០០០ រៀល និងជំពូក៦៥(ឧបត្ថម្ភធននិងជំនួយសង្គម) ចំនួន៦ ២២៧ ០០០ ០០០រៀល ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។

**មាត្រា២**: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីទូទាត់ជំហ៊ានទី២ លើការចំណាយរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី១៦ និងកិច្ចប្រជុំពាក់ព័ន្ធ សងនិងបង្វិលវិញជូនអង្គការ ក្រុមហ៊ុន សហគ្រាស និងបង្វែរជូនអង្គការស្បៀងអាហារពិភពលោកថ្លៃអង្ករ និងថវិកាទ្រទ្រង់ប្រតិបត្តិការឆ្នាំ២០១១។

**មាត្រា៣**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៩៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកាត់ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគ មកជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីសរុបចំនួន ៥.៦៣១ ហិកតា នៅភូមិព្រែនទឹង ឃុំឆ្នាល់មាន់ ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង និងធ្វើប្រទានកម្មជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ.បកចុះថ្ងៃទី០១ខែធ្នូ ឆ្នាំ២០០០ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការប្រឡងប្រណាំងកែលំអសោភ័ណភាពខេត្តទូទាំងប្រទេស
- បានឃើញសារាចរលេខ ០៥ សរ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- តាមសំណើលេខ ១១៩៩ ចុះថ្ងៃទី១៣ ខែ កញ្ញា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- តាមសំណើលេខ ១២៦២ ចុះថ្ងៃទី២៦ ខែ កញ្ញា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ចេញពីផែនទីគម្របព្រៃឈើ និងធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋ នូវចំណែកផ្ទៃដីសរុបចំនួន ៥.៦៣១ ហិកតា (ប្រាំពាន់ប្រាំមួយរយសាមសិបមួយហិកតា) ដែលក្នុងនោះកាត់ដីចេញពីដីព្រៃសម្បទាន ទំហំ ១.៧៨៤ ហិកតា ពីក្រុមហ៊ុន យូរីសាគរ (លិខិតលេខ ២២០ សជណ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ១៩៩៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី) និងគម្របព្រៃឈើដែលមានដីកាដកហូត (ដីកាលេខ ១៨២ ដក.អនគ ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៦ របស់ខេត្តបាត់ដំបង) នូវផ្ទៃដីទំហំ ៣.៨៤៧ ហិកតា មានទីតាំងស្ថិតនៅភូមិព្រៃទទឹង ឃុំឆ្នាល់មាន់ ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ដើម្បីធ្វើការគ្រប់គ្រងនិងប្រទានកម្មដោយផ្តល់នូវសិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិព្រៃទទឹង ឃុំឆ្នាល់មាន់ ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង លើក្បាលដីចំនួន ៩៦៨ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ៥៩៤ (ប្រាំរយកៅសិបបួន) គ្រួសារ ព្រមទាំង ០២ ក្បាលដី ជាដីសាលារៀន និង ០២ ក្បាលដីជាដីស្រះទឹក។

**មាត្រា ៣ .-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គមនៅក្នុងមូលដ្ឋាន។

**មាត្រា ៤ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល ៖***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ១៧០៥ . អនក្រ.បក**

## អនុក្រឹត្យ
## ស្តីពី
## ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ ៖** ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ ***វរសេនីយ៍ឯក*** ជូនលោកវរសេនីយ៍ទោ **សែត ចណ្ណារសិទ្ធិ** អត្តលេខ ០៥២១១ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង - ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែតុលា ឆ្នាំ ២០១២*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១២០៦.អនក្រ.តត

# អនុក្រឹត្យ

## ស្ដីពី

## ការតែងតាំងមុខតំណែងនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** ៖ ត្រូវបានតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ត្រី **កុសល គិរម្យ** អត្តលេខ ០៦៥៨ ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ**អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២** ៖ បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកញ្ញា ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ១២០៧. អនក្រ.តត**

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល
# នៃមន្ទីរពេទ្យកុមារជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១០ ស្តីពីការប្រែក្លាយមន្ទីរពេទ្យកុមារជាតិ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨៩៦ អនក្រ.តត ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១០ ស្តីពីការតែងតាំងសមាភាពក្រុមប្រឹក្សាភិបាលនៃមន្ទីរពេទ្យកុមារជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**មាត្រា១.-**

ត្រូវបានតែងតាំងលោក **ឡុង ឌីម៉ង់** បច្ចុប្បន្នជានាយកទីចាត់ការរដ្ឋបាលនៃសាលារាជធានីភ្នំពេញ

ជាសមាជិកក្រុមប្រឹក្សាភិបាលមន្ទីរពេទ្យកុមារជាតិ តំណាងសាលារាជធានីភ្នំពេញ ជំនួស លោក **គឹម សាខុធ** ដែលបានចូលនិវត្តន៍។

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា៣*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*